# អារម្ភកថា

ផ្អែកលើ “ទស្សនវិស័យអនាគតនៃសេដ្ឋកិច្ចពិភពលោក” របស់មូលនិធិរូបិយវត្ថុអន្តរជាតិ និងការសិក្សារបស់គ្រឹះស្ថានហិរញ្ញវត្ថុពហុភាគីសំខាន់ៗផ្សេងទៀត ដំណើរការសេដ្ឋកិច្ចពិភពលោកឆ្នាំ២០០៧ និងឆ្នាំ២០០៨ នឹងទទួលបាននូវការវាយតម្លៃល្អជាទូទៅប្រកបដោយសុទិដ្ឋិនិយម ។ ប្រទេសជាច្រើនមានសកម្មភាពសេដ្ឋកិច្ចប្រកបដោយភាពរីកចម្រើន និងឈានទៅរកតុល្យភាព ម្យ៉ាងដោយសារភាពធូរស្បើយនៃសម្ពាធថ្លៃប្រេងឥន្ធនៈ និងម្យ៉ាងទៀតអាស្រ័យដោយមានវិធានការសមស្របសម្រាប់ទប់ទល់ហានិភ័យ គួបផ្សំនឹងវិធានការលើកស្ទួយសេដ្ឋកិច្ច ដែលប្រទេសជាច្រើនបានប្រកាន់យក ។ ទិន្នន័យសេដ្ឋកិច្ចថ្មីៗបានបង្ហាញឱ្យឃើញថា កំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិកឆ្នាំ២០០៧ អាចនឹងមានកម្រិតទាបជាងឆ្នាំ២០០៦ បន្តិច ចំណែកឯនៅសហគមន៍អឺរ៉ុប មាននិន្នាការកើនឡើងជាងឆ្នាំមុន ។ ការងើបឡើងវិញនៃសេដ្ឋកិច្ចជប៉ុនក៏កាន់តែប្រសើរឡើង ដោយកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០០៧ ត្រូវបានព្យាករថានឹងខ្ពស់ជាងឆ្នាំមុនបន្តិច ។ កំណើននៃសេដ្ឋកិច្ចចម្បងៗផ្សេងទៀតនៅអាស៊ីក៏កំពុងមានសន្ទុះគួរឱ្យកត់សម្គាល់ដែរ ជាពិសេសប្រទេសចិន និងឥណ្ឌា ។ ទន្ទឹមនោះ ផ្អែកលើទិន្នន័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី កំណើនសេដ្ឋកិច្ចប្រទេសអាស៊ាន ជារួមអាចមានកម្រិត ៧,៧% នៅឆ្នាំ២០០៧ ធៀបនឹង ៨,៧% នៅឆ្នាំ២០០៦ ។ ជាទូទៅ ពិភពលោកមានសុទិដ្ឋិនិយមចំពោះវឌ្ឍនភាពសេដ្ឋកិច្ច និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុន្តែ ហានិ-ភ័យជាសក្តានុពលមួយចំនួនក៏ត្រូវបានកត់សម្គាល់ដែរ ដែលទាមទារនូវវិធានការផ្ទៃក្នុងសមស្រប ក៏ដូចជាការបង្កើន និងការពង្រឹងសហប្រតិបត្តិការអន្តរជាតិ ។

ដំណើរការសេដ្ឋកិច្ចពិភពលោក ពិសេសប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជាទាំងក្នុង និងក្រៅតំបន់មានឥទ្ធិពលជាច្រើនមកលើការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា ដែលជាប្រទេសកំពុងអភិវឌ្ឍមួយមានសេដ្ឋកិច្ចខ្នាតតូច និងបើកចំហ ។ កម្លាំងសេដ្ឋកិច្ចពិភពលោកដែលជះឥទ្ធិពលជាបឋមទៅលើវិស័យទេសចរណ៍ វិស័យពាណិជ្ជកម្មក្រៅប្រទេស លើទំនិញ ពិសេសការនាំចេញសម្លៀកបំពាក់ និងការវិនិយោគទុនបរទេស ជាកត្តារួមចំណែកដ៏ចម្បងចំពោះកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងពេលកន្លងមក ។ ដូច្នេះ សុទិដ្ឋិនិយមនៃទស្សនវិស័យសេដ្ឋកិច្ចពិភពលោកគឺជាកត្តាប្រកបដោយក្តីសង្ឃឹមមួយសម្រាប់ដំណើរការសេដ្ឋកិច្ចកម្ពុជា ។ ប្រការនេះ គួបផ្សំនឹងស្ថានភាពអំណោយផលនៃវិស័យកសិកម្មក្នុងស្រុកបានបង្កើតជាមូលដ្ឋានដ៏រឹងមាំសម្រាប់គាំទ្រការប៉ាន់ស្មានថា សេដ្ឋកិច្ចកម្ពុជានឹងមានកំណើនប្រមាណ ៩,១% ក្នុងឆ្នាំ២០០៧ ហើយនាឆ្នាំខាងមុខ នៅតែមានកម្រិតខ្ពស់ជាងមធ្យមភាគនៃកំណើនក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ។

ក្នុងឆមាសទី១ នេះ ស្ថានភាពវិស័យធនាគារនិងហិរញ្ញវត្ថុក៏បង្ហាញនូវភាពកាន់តែប្រសើរឡើង ដែលទ្រទ្រង់ដោយកម្រិតអតិផរណាដ៏ទាប និងស្ថិរភាពអត្រាប្តូរប្រាក់រៀល ។ អាស្រ័យដោយការថយចុះនៃសម្ពាធថ្លៃប្រេងលើទីផ្សារពិភពលោក កម្រិតអតិផរណាទាបនៅតាមប្រទេសផ្គត់ផ្គង់ទំនិញសម្រាប់កម្ពុជា រួមទាំងអំណោយផលនៃវិស័យកសិកម្មក្នុងស្រុក អតិផរណានៃថ្លៃទំនិញប្រើប្រាស់នៅកម្ពុជានាឆមាសទី១ ផ្អែកលើសន្ទស្សន៍ថ្លៃទំនិញមធ្យម

រំកិលបីខែ ស្មើនឹង ២.៩% ធៀបនឹង ៣.៤% នាខែធ្នូ ឆ្នាំ២០០៦ និង ៤.៥% ខែមិថុនា ឆ្នាំ២០០៦ ។ ក្នុងអំឡុងពេលនេះដែរ ចលនានៃអត្រាប្តូរប្រាក់នៅលើទីផ្សារប្តូរប្រាក់កម្ពុជាបានបង្ហាញឱ្យឃើញនូវកំណើនតម្រូវការប្រាក់រៀលគួរឱ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងតាមរយៈនិន្នាការឡើងថ្លៃនៃប្រាក់រៀល ព្រមទាំងអន្តរាគមន៍យ៉ាងសកម្មនៅលើទីផ្សារប្តូរប្រាក់ សំដៅស្រូបយករូបិយប័ណ្ណ និងរក្សាស្ថិរភាពតម្លៃរូបិយវត្ថុជាតិ ។ ជារួម តម្លៃប្រាក់រៀលបានប្រែប្រួលជាមធ្យមក្នុងចន្លោះមួយតិចជាង ១% ក្នុងរយៈពេល៦ខែដើមឆ្នាំ២០០៧ នេះ ពោលគឺមានស្ថិរភាពដូចឆ្នាំកន្លងទៅដែរ ។ ទន្ទឹមនោះ វេគ្គិលជុំ (velocity) នៃប្រាក់រៀលបានបន្តធ្លាក់ចុះប្រមាណ ៥% ក្នុងរយៈពេល៦ខែនេះ ជាកត្តាឆ្លុះបញ្ចាំងឱ្យឃើញពីការបន្តកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើរូបិយវត្ថុជាតិ ដែលនឹងរួមចំណែកដល់ការអនុវត្តគោលនយោបាយជំរុញការប្រើប្រាស់រូបិយវត្ថុជាតិ ។ ការវិវត្តនៃកម្រិតថ្លៃទំនិញ និងអត្រាប្តូរប្រាក់ដូចបានលើកឡើងនេះ ក៏ត្រូវបានទ្រទ្រង់ផងដែរដោយ ការអនុវត្តប្រកបដោយអំណោយផលនៃប្រតិបត្តិការពាណិជ្ជកម្មក្រៅប្រទេស និងគោលនយោបាយសារពើពន្ធ ។ ថ្វីបើ ជញ្ជីងពាណិជ្ជកម្មនាឆមាសទី១ ឆ្នាំ២០០៧ ត្រូវបានព្យាករថាមានឱនភាពខ្ពស់ជាងរយៈពេលដូចគ្នានៃឆ្នាំមុនបន្តិចក្តី ប៉ុន្តែសមតុល្យរួមនៅតែរក្សាបាននូវភាពវិជ្ជមានក្នុងចំនួនប្រមាណ ១៤២,៩លានដុល្លារអាមេរិក ខណៈដែលការវិនិយោគផ្ទាល់បរទេសត្រូវបានប៉ាន់ស្មានថាកើនឡើង ២២% ធៀបនឹង៦ខែឆ្នាំមុន ដែលជាភាពប្រសើរឡើងគួរជាទីមោទនៈ ។ ទន្ទឹមនោះដែរ ទុនបម្រុងអន្តរជាតិកំពុងបន្តកើនឡើងជាលំដាប់ ហើយឈានដល់កម្រិតលើសពី ១.៣០០លានដុល្លារអាមេរិកនាបច្ចុប្បន្ននេះ និងអាចធានាឱ្យការនាំចូលបានប្រមាណបីខែ ។

ជាការពិត ការរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចប្រកបដោយចីរភាព សំដៅជំរុញសកម្មភាពសេដ្ឋកិច្ចជាតិ គឺជាផ្នែកសំខាន់មួយនៃភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ។ ក្រៅពីនេះ ភារកិច្ចចម្បងផ្សេងទៀត ពិសេសការពង្រឹង និងរក្សាស្ថិរភាពវិស័យធនាគារនិងហិរញ្ញវត្ថុ គឺជាកម្មវត្ថុសំខាន់នៃការយកចិត្តទុកដាក់ខ្ពស់របស់ធនាគារជាតិនៃកម្ពុជា ។ ដើម្បីសម្រេចនូវភារកិច្ចនេះ ការបន្តពង្រឹងនិងពង្រីកប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ដើម្បីផ្តល់សេវាចាំបាច់ដ៏សម្បូរបែប ព្រមទាំងប្រកបដោយគុណភាពចំពោះសេដ្ឋកិច្ច នៅតែជាការងារដ៏សំខាន់ដែលត្រូវតែយកចិត្តទុកដាក់ជាអចិន្ត្រៃយ៍ ។ មកទល់បច្ចុប្បន្ននេះ កម្មវិធីកំណែទម្រង់ដូចមានចែងនៅក្នុង “ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០” បានឈានដល់ដំណាក់កាលបញ្ចប់នៃអនុកម្មវិធីទីបីហើយ ព្រមទាំងមានសន្ទុះថែមមួយកម្រិតទៀត តាមរយៈការធ្វើបច្ចុប្បន្នកម្មទៅជា “យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥” ។ ឯកសារយុទ្ធសាស្ត្រថ្មីនេះ ត្រូវបានរាជរដ្ឋាភិបាលប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការយ៉ាងឱឡារិកនៅក្នុងសន្និសីទជាតិ នាខែមិថុនា ឆ្នាំ២០០៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ។ កម្មវិធីឥណទានថ្មីមួយទៀតពីធនាគារអភិវឌ្ឍន៍អាស៊ីកំពុងត្រូវបានរៀបចំ ដែលរួមជាមួយជំនួយបច្ចេកទេស ។

ក្នុងបរិបទនៃការពង្រឹងវិស័យធនាគារនិងហិរញ្ញវត្ថុនេះដែរ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងក្របខ័ណ្ឌច្បាប់ បទប្បញ្ញត្តិ ព្រមទាំងក្របខ័ណ្ឌស្ថាប័នសម្រាប់ការត្រួតពិនិត្យធនាគារ តាមរយៈការជំរុញតាមដានធនាគារឱ្យអនុវត្តបានពេញលេញជាប្រចាំនូវប្លង់គណនីឯកភាពដែលរៀបចំឡើងផ្អែកតាមស្តង់ដារអន្តរជាតិ ព្រមទាំងការបន្តកែ

លំអខ្លឹមសារនៃប្រកាស និងបទប្បញ្ញត្តិសំខាន់ៗនានា ដើម្បីជំរុញតម្លាភាព និងសម្រួលដល់ការអនុវត្ត ។ ទន្ទឹមនោះ ការលើកកម្ពស់ស្តង់ដារត្រួតពិនិត្យប្រុងប្រយ័ត្នកំពុងត្រូវបានជំរុញ ដើម្បីឈានទៅរកការសម្រេចបាននូវស្តង់ដារអន្តរជាតិនាអនាគត ។ បច្ចុប្បន្ន យើងកំពុងដាក់ឱ្យដំណើរការអនុវត្តសាកល្បងកម្មវិធីកុំព្យូទ័រកូប្រា (COBRA) ដែលជាឧបករណ៍ដ៏សំខាន់ក្នុងការជួយសម្រួលដល់ការវិភាគស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនីមួយៗ ក៏ដូចជាជួយបំពេញបន្ថែមទៀតទៅលើសមត្ថភាពត្រួតពិនិត្យដល់ទីកន្លែង ដែលត្រូវបានពង្រឹងជាលំដាប់ ។ ការលើកកម្ពស់ជាប្រចាំនូវការត្រួតពិនិត្យក៏ត្រូវបានអនុវត្តផងដែរចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គួបផ្សំនឹងការអនុវត្តនូវវិធានការទ្រទ្រង់ផ្សេងៗ ក្នុងគោលបំណងអភិវឌ្ឍប្រព័ន្ធមីក្រូហិរញ្ញវត្ថុមួយប្រកបដោយប្រសិទ្ធភាព និងចីរភាព ដែលនឹងផ្តល់សេវាហិរញ្ញវត្ថុក្នុងតម្លៃសមស្របមួយដែល ពលរដ្ឋក្រីក្រអាចទទួលយកបាន និងឆ្ពោះទៅរកជនបទ ។

ដើម្បីជំរុញការផ្តល់ឥណទានចំពោះវិស័យសេដ្ឋកិច្ច ជាបឋមចំពោះសហគ្រាសធុនតូចនិងមធ្យម ប្រព័ន្ធចែករំលែកព័ត៌មានឥណទានដែលផ្តល់លទ្ធភាពឱ្យធនាគារជាសមាជិកផ្លាស់ប្តូរព័ត៌មានឥណទានអវិជ្ជមាន ត្រូវបានបង្កើតឡើងនាឆ្នាំ២០០៦ ហើយបច្ចុប្បន្នកំពុងដំណើរការដោយរលូនស្របតាមការរំពឹងទុក ។ ប្រព័ន្ធនេះនឹងត្រូវកែលំអ ដើម្បីឱ្យបានជាប្រព័ន្ធមួយដែលមានប្រសិទ្ធភាព និងមានផលប្រយោជន៍ដល់គ្រប់សមាជិកទាំងអស់ដែលបានចូលរួម ។

ចំពោះការងារហេដ្ឋារចនាសម្ព័ន្ធច្បាប់ សមិទ្ធផលដ៏សំខាន់មួយទៀតនាឆមាសទី ១ នេះ គឺការអនុម័តពីសំណាក់ស្ថាប័ននីតិបញ្ញត្តិនូវសេចក្តីព្រាងច្បាប់ស្តីពី “ការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម” ។ ការអនុម័តច្បាប់នេះមិនត្រឹមតែជួយលើកកម្ពស់កិត្តិនាមប្រទេសកម្ពុជាប៉ុណ្ណោះទេ និងថែមទាំងរួមចំណែកទាក់ទាញវិនិយោគបរទេសមកក្នុងសេដ្ឋកិច្ច ។ ជំហានបន្ទាប់គឺការអនុវត្តច្បាប់នេះ ដោយការរៀបចំអនុក្រឹត្យ ប្រកាស និងបទប្បញ្ញត្តិចាំបាច់ផ្សេងៗ ការបង្កើតឡើងនូវអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ការបណ្តុះបណ្តាល ព្រមទាំងការផ្សព្វផ្សាយអំពីខ្លឹមសារនិងកាតព្វកិច្ចពាក់ព័ន្ធនានា ។ ដោយឡែក ការរៀបចំសេចក្តីព្រាងច្បាប់ភតិសន្យាកំពុងត្រូវបានសំអិតសំអាងឱ្យសុក្រឹត និងឈានដល់ដំណាក់កាលជិតបញ្ចប់ហើយដែរ ។

អាទិភាពសំខាន់មួយទៀត គឺការអភិវឌ្ឍប្រព័ន្ធទូទាត់ជាតិមួយដែលមានប្រសិទ្ធភាព ។ ក្នុងស្មារតីនេះ ការរៀបចំនូវផែនទីចង្អុលផ្លូវមួយកំពុងត្រូវបានរៀបចំ ដើម្បីចង្អុលបង្ហាញអំពីអាទិភាពការងារដែលត្រូវអនុវត្តតាមលំដាប់លំដោយក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់នេះ ។ ការវិនិយោគលើប្រព័ន្ធព័ត៌មានវិទ្យាដើម្បីធ្វើស្វ័យប្រវត្តិកម្មនូវប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជា ក៏ជាអាទិភាពសំខាន់មួយទៀតដែលកំពុងតែរៀបចំអភិវឌ្ឍន៍ ។

ក្រៅអំពីនោះ ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង និងការកែទម្រង់រចនាសម្ព័ន្ធផ្ទៃក្នុង ក៏ជាសកម្មភាពដ៏ចម្បងផងដែររបស់ធនាគារជាតិនៃកម្ពុជា ក្នុងឆមាសទី ១ ឆ្នាំ ២០០៧ ក៏ដូចជាចំពោះអំឡុងពេលទៅមុខ ។ ជាមួយគ្នានេះដែរ ក្នុងស្មារតីចូលរួមក្នុងដំណើរការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចពិភពលោកនិងតំបន់ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តផ្តោតការយកចិត្តទុក

ដាក់ថែមទៀតលើការលើកកម្ពស់ និងការពង្រីកសហប្រតិបត្តិការអន្តរជាតិលើវិស័យហិរញ្ញវត្ថុ ទាំងក្នុងក្របខ័ណ្ឌអាស៊ាន១០ អាស៊ានជាមួយប្រទេសដៃគូ ក៏ដូចជាជាមួយស្ថាប័នហិរញ្ញវត្ថុពហុនិងទ្វេភាគីដទៃទៀតដែរ ។

សមិទ្ធផលដូចដែលបានរៀបរាប់ពីខាងលើ គឺជាផ្លែផ្កាគួរជាទីមោទនៈនៃកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា គួបផ្សំនឹងកិច្ចសហប្រតិបត្តិការពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ទាំងក្នុងនិងក្រៅប្រទេស ។ ទន្ទឹមនោះ នៅមានបញ្ហាប្រឈមចំពោះមុខជាច្រើនទៀតដែលត្រូវពុះពារជំនះ ដើម្បីសម្រេចឱ្យបាននូវទិសដៅ និងផែនការទាំងឡាយដែលបានលើកឡើងនៅក្នុងគោលនយោបាយនានា និងផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ។

នៅទីបញ្ចប់ ខ្ញុំសូមឆ្លៀតឱកាសនេះសម្តែងការអរគុណចំពោះក្រុមប្រឹក្សាភិបាល មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ចំពោះការលះបង់ស្ម័គ្រស្មោះ និងឧស្សាហ៍ព្យាយាមក្នុងការងារ ។ ប្រសិនបើគ្មានការចូលរួមទាំងនោះទេ សមិទ្ធផលទាំងឡាយដែលបានលើកឡើងលំអិតនៅក្នុងរបាយការណ៍នេះនឹងពុំអាចកើតមានឡើងបានឡើយ ។ ខ្ញុំសង្ឃឹមជឿជាក់យ៉ាងមាំថា មន្ត្រីបុគ្គលិកទាំងអស់នឹងបន្តដើរតួនាទីយ៉ាងសកម្មថែមទៀត ដើម្បីធានាបំពេញឱ្យបានយ៉ាងល្អនូវមុខងារ-ភារកិច្ចទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា ។

**ទេសាភិបាល**

# មាតិកា

ទំព័រ


ក. របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០០៧ ១

សេចក្តីផ្តើម ២

I. ការវិវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ៤

១. ស្ថានភាពតម្លៃប្រាក់រៀល ៤

១.១. ការវិវត្តសន្ទស្សន៍ថ្លៃទំនិញ និងសេវា (CPI) ៤

១.២. ស្ថានភាពអត្រាប្តូរប្រាក់ ៧

១.២.១. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ៧

១.២.២. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗ ៨

២. ការវិវត្តរូបិយវត្ថុ ៩

២.១. ការផ្គត់ផ្គង់រូបិយវត្ថុ ៩

២.២. កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ ១០

២.២.១. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ១១

២.២.២. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ ១១

៣. ជញ្ជីងទូទាត់ ១២

៣.១. គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) ១២

៣.២. គណនីដើមទុន និងហិរញ្ញវត្ថុ ១៤

៤. ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ១៥

៤.១. ការវិនិយោគទុនបម្រុងអន្តរជាតិ ១៥

៤.២. អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ១៥

៤.៣. ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់ ១៦

៥. សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៦

៥.១. ការត្រួតពិនិត្យធនាគារពាណិជ្ជ និងធនាគារឯកទេស ១៦

៥.១.១. ការត្រួតពិនិត្យលើឯកសារ ១៦

៥.១.២. ការត្រួតពិនិត្យដល់ទីកន្លែង ១៧

៥.២. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ១៧

៥.៣. ការជម្រះបញ្ជីធនាគារ ១៨

៥.៤- ការងាររៀបចំបទបញ្ញា ១៨

៥.៥- អាជ្ញាប័ណ្ណ និងចុះបញ្ជី ១៨

៥.៦- ចំណូលពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងស្លាកការគណនី ១៩

៦- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល ១៩

៦.១- សេវាផ្នែកគណនី ១៩

៦.១.១- សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ ១៩

៦.១.២- ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរដ្ឋាភិបាល ២០

៦.១.២.១- ហិរញ្ញប្បទាន និងកម្ចី របស់រាជរដ្ឋាភិបាលជប៉ុន ២០

៦.១.៣- សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ២១

៦.២- សេវាទូទាត់ទាត់ ២១

៦.២.១- ការទូទាត់ទាត់មូលប្បទានប័ត្រចរាចរជាប្រាក់រៀល ២១

៦.២.២- ការទូទាត់ទាត់មូលប្បទានប័ត្រចរាចរជាប្រាក់ដុល្លារអាមេរិក ២២

៦.៣- ការងារឥណទាន ២២

៧- ការគ្រប់គ្រងចរាចរណ៍ធនប័ត្រ ២២

II. ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ២៣

១- សកម្មភាពក្រុមប្រឹក្សាភិបាល ២៣

២- ការអភិវឌ្ឍធនធានមនុស្ស ២៤

២.១- ស្ថិតិមន្ត្រី-បុគ្គលិក ២៤

២.២- ការងារបណ្តុះបណ្តាល ២៤

៣- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ២៦

៤- ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា ២៧

៥- ការងារគណនេយ្យធនាគារជាតិនៃកម្ពុជា ២៨

III. ទំនាក់ទំនងអន្តរជាតិ ២៩

១- ទំនាក់ទំនងពហុភាគី ២៩

១.១- ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ ២៩

១.២- ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ៣០

១.៣- ទំនាក់ទំនងជាមួយអាស៊ាន ៣១

១.៤. ទំនាក់ទំនងជាមួយ SEACEN ៣១
១.៥. ទំនាក់ទំនងជាមួយក្រុមអាស៊ីប៉ាស៊ីហ្វិក (APG) ៣២
១.៦. ទំនាក់ទំនងជាមួយសមាគមឥណទានកសិកម្ម និងឥណទានជនបទតំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA) ៣២
២. ទំនាក់ទំនងទ្វេភាគី ៣៣
សន្និដ្ឋាន ៣៤
ខ. ទិសដៅការងារឆមាសទី២ ឆ្នាំ២០០៧ ៣៦
ទិសដៅការងារឆមាសទី២ ឆ្នាំ២០០៧ ៣៧
១. ការងាររូបិយវត្ថុ ៣៧
២. ការងារប្តូរប្រាក់ ៣៧
៣. ការអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ ៣៧
៤. ការងារត្រួតពិនិត្យ ៣៨
៥. ការងារប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ៣៨
៦. ការងារគណនេយ្យ ៣៨
៧. ការងារប្រតិបត្តិការ ៣៨
៨. ការងារបោះផ្សាយ និងឃ្លាំងបេឡា ៣៩
៩. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ៣៩
១០. ការបណ្តុះបណ្តាល ៣៩
ឧបសម្ព័ន្ធ ៤០
ឧបសម្ព័ន្ធ ១ : សន្ទស្សន៍ថ្លៃទំនិញ និងសេវា ឆ្នាំ២០០៤-ឆមាសទី១ ឆ្នាំ២០០៧ ៤១
ឧបសម្ព័ន្ធ ២ : ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ ៤២
ឧបសម្ព័ន្ធ ៣ : ស្ថានភាពរូបិយវត្ថុ (គិតជាពាន់លានរៀល) ៤៣
ឧបសម្ព័ន្ធ ៤ : ស្ថានភាពរូបិយវត្ថុ (បម្រែបម្រួលប្រចាំខែជាភាគរយ) ៤៤
ឧបសម្ព័ន្ធ ៥ : តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា ៤៥
ឧបសម្ព័ន្ធ ៦ : តារាងគណនីវិភាគធនាគារពាណិជ្ជ ៤៦
ឧបសម្ព័ន្ធ ៧ : ឥណទានចំណាត់ថ្នាក់តាមមុខរបរ និងសរុបប្រតិបត្តិការប្រាក់បញ្ញើធនាគារពាណិជ្ជ ៤៧
ឧបសម្ព័ន្ធ ៨ : ជញ្ជីងទូទាត់ប្រទេសកម្ពុជា ឆ្នាំ២០០៤ — ឆមាសទី១ ឆ្នាំ២០០៧ ៤៨

# ក. របាយការណ៍ប្រចាំឆមាសទី១

# ឆ្នាំ២០០៧

# សេចក្ដីផ្ដើម

រយៈពេលប្រាំមួយខែដើមឆ្នាំ២០០៧ បានចាប់ផ្ដើមឡើងក្នុងដំណាក់កាលដែលពោរពេញដោយសុទិដ្ឋិនិយម ចំពោះដំណើរការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា ។ ការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០០៦-២០១០ បាននាំមកនូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការបង្កើតកំណើន សេដ្ឋកិច្ចនៅលើមូលដ្ឋានដ៏ទូលំទូលាយទូទាំងផ្ទៃប្រទេស និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជាជា បណ្ដើរៗ ។ តាមរយៈការអនុវត្តភារកិច្ចដែលច្បាប់បានប្រគល់ឱ្យ ធនាគារជាតិនៃកម្ពុជាក៏បានខិតខំរួមចំណែកដើម្បី សម្រេចគោលដៅរួមរបស់ជាតិដែរ ។ ផ្អែកលើគោលនយោបាយគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយ័ត្ន និងប្រកប ដោយលក្ខណៈទន់ភ្លន់ សេដ្ឋកិច្ចកម្ពុជាទទួលបាននូវកំណើនដ៏ខ្ពស់នៅឆ្នាំ២០០៥ និង២០០៦ ។ ដំណើរការសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៧ នេះ ត្រូវបានព្យាករថានឹងមានកម្រិតទាបជាងឆ្នាំកន្លងទៅបន្តិច ដែលជាបឋមអាចបណ្ដាលមកពីការ ថមថយសន្ទុះនៃកំណើនវិស័យកសិកម្ម និងកម្រិតនៅខ្ពស់នៃថ្លៃថាមពលក្នុងប្រទេស ទោះបីសម្ពាធថ្លៃប្រេងឥន្ធនៈ នៅលើទីផ្សារពិភពលោកបានថយចុះខ្លះក្ដី ។ ប៉ុន្តែទោះជាដូច្នេះក្ដី ក៏កំណើនផលិតផលក្នុងស្រុកសរុបរបស់ប្រទេស កម្ពុជាជាទូទៅនៅតែត្រូវបានរំពឹងថានឹងបន្តភាពរឹងមាំក្នុងកម្រិតប្រមាណ ៩,១% ដែរ ។ នេះជាកម្រិតកំណើនដ៏ លើកទឹកចិត្តមួយ ពិសេសបើធៀបនឹងកំណើនសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាច្រើនទាំងក្នុងនិងក្រៅតំបន់ ។

សូចនាករម៉ាក្រូសេដ្ឋកិច្ចដទៃទៀតនាឆមាសទី ១ នេះ ក៏បង្ហាញនូវសញ្ញាទ្រទ្រង់ដ៏ច្រើនចំពោះការអភិវឌ្ឍ សេដ្ឋកិច្ចដែរ ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នៅក្នុងខែមេសាកន្លងមក ជាព្រឹត្តិការណ៍ដ៏សំខាន់មួយ ដែលពុំបានជះឥទ្ធិពលអវិជ្ជមានទៅលើស្ថិរភាពទូទៅនៃម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពវិស័យហិរញ្ញវត្ថុឡើយ ។ អត្រា ប្ដូរប្រាក់នាអំឡុងពេល៦ខែ ដើមឆ្នាំនេះ មានការប្រែប្រួលតិចតួច ខណៈដែលសម្ពាធអតិផរណាដែលវាស់ដោយ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់មធ្យមបីខែ បានបង្ហាញនូវនិន្នាការថយចុះគួរឱ្យកត់សម្គាល់ ។ ប្រតិបត្តិការ ជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះត្រូវបានប៉ាន់ស្មានថា មានលទ្ធផលប្រហែលនឹងឆមាស ទី១ ឆ្នាំ២០០៦ ដោយសមតុល្យរួមមានអតិរេកប្រមាណ ១៤២,៩លានដុល្លារអាមេរិក ។ លើសពីនេះទៀត ទុន បម្រុងអន្តរជាតិបានបន្តកើនឡើងជាលំដាប់ក្នុងល្បឿនមួយខ្ពស់ជាងឆ្នាំមុន នៅពេលដែលទិន្នន័យវិស័យរូបិយវត្ថុ បានបង្ហាញនូវប្រតិបត្តិការយ៉ាងសកម្មនៃគ្រឹះស្ថានហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងតាមរយៈការបង្កើនដើមទុនធនាគារ កំណើនឥណទានចំពោះវិស័យឯកជន និងកំណើនប្រាក់បញ្ញើរបស់អតិថិជន ក្នុងល្បឿនមួយដ៏គួរឱ្យកត់សម្គាល់ ។

ចំពោះសមិទ្ធផលនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុវិញ ក្រៅពីការចូលរួមក្នុងការពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារ ជាតិនៃកម្ពុជាបានបន្តអនុវត្តយ៉ាងសកម្មនូវកម្មវិធីកំណែទម្រង់ទាំងឡាយ ដូចមានចែងនៅក្នុង “ចក្ខុវិស័យ និង ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០” ។ ក្នុងនោះរួមមាន ការពង្រឹងក្របខ័ណ្ឌច្បាប់ដែលមិនអាចខ្វះ បាន សម្រាប់ការកសាងប្រព័ន្ធធនាគារមួយប្រកបដោយប្រសិទ្ធភាព ការបន្តពង្រឹងប្រព័ន្ធធនាគារតាមរយៈការលើក កម្ពស់គុណភាព ការត្រួតពិនិត្យលើឯកសារ និងការចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជ ព្រមទាំង

ការកែលំអ និងដាក់ឱ្យអនុវត្តនូវបទដ្ឋានប្រុងប្រយ័ត្នផ្សេងៗ ។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធច្បាប់ និងស្ថាប័នសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ក៏ត្រូវបានអនុវត្តបន្តជាលំដាប់ ហើយបានទទួលនូវការយកចិត្តទុកដាក់ ព្រមទាំងការចូលរួមជាច្រើនពីសំណាក់មជ្ឈដ្ឋានមានចំណាប់អារម្មណ៍ទាំងឡាយ ទាំងក្នុងនិងក្រៅប្រទេស ។

វឌ្ឍនភាពក្នុងវិស័យហិរញ្ញវត្ថុមកទល់បច្ចុប្បន្ន បានផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលឱ្យជំរុញសន្ទុះនៃកំណែទម្រង់ក្នុងវិស័យនេះមួយកម្រិតទៀត តាមរយៈការធ្វើបច្ចុប្បន្នកម្ម “ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០” ទៅជា “ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥” ដែលជាផ្នែកមួយនៃឯកសារយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងការបង្កើតកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា ។

# I. ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា

## ១. ស្ថានភាពថ្លៃនិងតម្លៃប្រាក់រៀល

### ១.១. ការវិវត្តសន្ទស្សន៍ថ្លៃទំនិញ និងសេវា (CPI)

អត្រាអតិផរណាប្រចាំឆ្នាំ ផ្អែកលើបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) រំកិលបីខែ បានចាប់ផ្តើមឆមាសទី១ ឆ្នាំ២០០៧ ក្នុងកម្រិតមួយដ៏ទាប ស្មើនឹង ២,៩% ធៀបនឹង ៦,៥% និង ៥,៧% នាខែមករា ឆ្នាំ២០០៦ និងឆ្នាំ២០០៥ រៀងគ្នា ។ នេះជាលទ្ធផលនៃការថមថយចុះនៃសម្ពាធថ្លៃម្ហូបអាហារ និងជាពិសេសថ្លៃប្រេងឥន្ធនៈ ដែលបានកើនឡើងក្នុងល្បឿនយ៉ាងលឿនចាប់តាំងពីចុងឆ្នាំ២០០៥ ព្រមទាំងបន្តមកឆ្នាំ២០០៦ ។




ដោយឡែក បើពិនិត្យការវិវត្តសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តាមរយៈបម្រែបម្រួលប្រចាំខែវិញឃើញថា ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៧ អតិផរណាមាននិន្នាការកើនឡើងពីមួយខែទៅមួយខែ ក្នុងល្បឿនមួយខ្ពស់ជាងក្នុងឆមាសទី១ ឆ្នាំមុនបន្តិច ។ សន្ទស្សន៍ថ្លៃបានថយចុះបន្តិចក្នុងខែមករា ឆ្នាំ២០០៧ ធៀបនឹងខែធ្នូ ឆ្នាំ២០០៦ បន្ទាប់មកបានបង្ហាញនិន្នាការកើនឡើងវិញជាបន្តបន្ទាប់ក្នុងសន្ទុះសន្សឹមៗ រហូតដល់ដំណាច់ឆមាសទី ១ នេះ ។ សម្ពាធអតិផរណាប្រចាំខែបណ្តាលជាចម្បងមកពីការងើបឡើងវិញខ្លះៗនៃថ្លៃប្រេងឥន្ធនៈ និងថ្លៃគ្រឿងឧបភោគបរិភោគ សម្លៀកបំពាក់ ព្រមទាំងសម្ភារៈប្រើប្រាស់មួយចំនួន ។




សន្ទស្សន៍ថ្លៃទំនិញបានកើនជាបណ្តើរៗចាប់តាំងពីខែកុម្ភៈមក ដោយបានកើនឡើងដល់ ១២៤,0៩ ក្នុងខែមិថុនា ឆ្នាំ២00៧ ធៀបនឹង ១២១,៤៦ ក្នុងខែធ្នូ ឆ្នាំ ២00៦ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងបម្រែបម្រួលជាវិជ្ជមាននៃសន្ទស្សន៍រងមួយចំនួន ។ ការប្រៀបធៀបអត្រាមធ្យមប្រចាំខែ ចំពោះឆមាសទី១ ឆ្នាំនេះ ជាមួយឆមាសទី១ និងឆមាសទី២ ឆ្នាំ២00៦ បង្ហាញថាសន្ទស្សន៍រងម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ បានកើនឡើងច្រើនជាងគេ ចំនួន 0,៦% ជាពិសេសដោយសារកំណើនថ្លៃត្រី គួបផ្សំនឹងការកើនឡើងនៃថ្លៃសាច់បសុបក្សី សាច់គោ សាច់ជ្រូក និងប្រេងឆា ។ បន្ទាប់មកគឺ

**អត្រាមធ្យមប្រចាំខែ  ក្នុងឆមាស**

| | ២00៦ | | ២00៧ |
|---|---|---|---|
| | ឆមាសទី ១ | ឆមាសទី២ | ឆមាសទី ១ |
| មុខទំនិញគ្រប់មុខ | 0,២២ | 0,២៥ | 0,៣៦ |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | 0,0៨ | 0,២៦ | 0,៦0 |
| សម្លៀកបំពាក់ និងស្បែកជើង | 0,២៨ | 0,១៥ | 0,៤១ |
| ផ្ទះសំបែងនិងការប្រើប្រាស់ | 0,២៤ | 0,២៧ | 0,១៩ |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | 0,១២ | 0,២0 | 0,២៦ |
| ការថែទាំសុខភាព | 0,៣៦ | 0,0៣ | -0.0៦ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | 0,៨២ | 0,៣៨ | 0,២៥ |
| ការកំសាន្ត និងអប់រំ | 0,0៧ | 0,0៦ | 0,0៤ |
| ការថែទាំខ្លួន និងសេវាកម្មផ្ទាល់ខ្លួន | 0,១៩ | 0,0៦ | 0,១៩ |

សន្ទស្សន៍រងសម្លៀកបំពាក់ និងស្បែកជើង កើនចំនួន 0,៤% ។ ចំណែកសន្ទស្សន៍រងគ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ក្នុងផ្ទះ ព្រមទាំងសន្ទស្សន៍រងដឹកជញ្ជូននិងទូរគមនាគមន៍វិញ បានកើនប្រមាណ 0,២៥% ។ គួរចាប់អារម្មណ៍ដែរថា ចំពោះថ្លៃសេវាដឹកជញ្ជូននិងទូរគមនាគមន៍ ថ្វីបើមានការកើនឡើងក្នុងឆមាសទី ១ នេះក្តី ប៉ុន្តែនៅមានកម្រិតទាបជាងឆមាសដូចគ្នានៃឆ្នាំមុន ។ សន្ទស្សន៍រងផ្ទះសំបែង និងការប្រើប្រាស់សន្ទស្សន៍រងការថែទាំខ្លួន និងសេវាកម្មផ្ទាល់ខ្លួនមានកំណើន 0,១៩% ខណៈដែលសន្ទស្សន៍រងផ្សេងទៀតដែលនៅសល់មានការប្រែប្រួលតិចតួច ។

## ក្រាហ្វិក ៣ ៖ ការប្រៀបធៀបចលនាអតិផរណា ផ្អែកលើរង្វាស់ផ្សេងៗ




## ក្រាហ្វិក ៤ ៖ បម្រែបម្រួលសន្ទស្សន៍រថថ្លៃទំនិញប្រើប្រាស់ និងសេវា

(បម្រែបម្រួលជាភាគរយ ខែលើខែ)



## ១.២. ស្ថានភាពអត្រាប្តូរប្រាក់

### ១.២.១. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក

អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកក្នុងឆមាសទី១ ឆ្នាំ២០០៧ បានបង្ហាញនូវស្ថិរភាពគួរឱ្យកត់សម្គាល់ ធៀបនឹងចលនាប្រែប្រួលដ៏ខ្ពស់នាឆមាសដូចគ្នានៃឆ្នាំកន្លងទៅ ។ ប្រាក់រៀលបានចាប់ផ្តើមឆ្នាំ២០០៧ ដោយអត្រាមធ្យមស្មើនឹង ៤.០៦៥រៀល ក្នុង១ដុល្លារអាមេរិក នាខែមករា ឆ្នាំ២០០៧ ធៀបនឹង ៤.០៩២រៀល នាខែមករា ឆ្នាំ២០០៦ ។ តម្រូវការប្រាក់រៀលនៅមុនរដូវចូលឆ្នាំប្រពៃណីខ្មែរ បានជំរុញឱ្យប្រាក់រៀលឡើងថ្លៃជាបង្គួរ រហូតដល់ ៤.០៤០រៀល ក្នុង១ដុល្លារអាមេរិក ដែលជាអត្រាទាបជាងគេប្រចាំឆមាស ។ បន្ទាប់មក អត្រាប្តូរប្រាក់បានរងសម្ពាធខ្លះវិញ ខណៈដែលរដូវប្រមូលផលកន្លងហួស ។ អត្រាទិញទីផ្សារចុងគ្រា ក្នុង ១ដុល្លារអាមេរិក បានកើនឡើងពី ៤,០៥៨ រៀល ក្នុងខែធ្នូ ឆ្នាំ២០០៦ មក ៤.០៨៩រៀល ក្នុងខែមិថុនា ឆ្នាំ២០០៧ ពោលគឺប្រាក់រៀលបានធ្លាក់ថ្លៃ ០,៨% ក្នុងឆមាសនេះ ។ ពិនិត្យលើក្រាហ្វិកនៃអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ចំពោះរយៈពេលឆមាសទី១ នៃឆ្នាំ២០០៥-២០០៧ បង្ហាញថា ការវិវត្តនៃអត្រាប្តូរប្រាក់រៀលមាននិន្នាការប្រហាក់ប្រហែលគ្នា ពោលគឺប្រាក់រៀលច្រើនមានស្ថិរភាពនាដើមឆ្នាំ តែចាប់ផ្តើមធ្លាក់ថ្លៃចាប់ពីពាក់កណ្តាលខែមេសារហូតដល់ខែមិថុនា ដែលមូលហេតុចម្បងបណ្តាលមកពីកត្តារដូវកាល ។

**ក្រាហ្វិក ៤ : ការវិវត្តនៃអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក**

**(អត្រាទិញទីផ្សារ ប្រចាំថ្ងៃ)**



## តារាងអត្រាប្តូរប្រាក់រៀល ធៀបនឹងប្រាក់ដុល្លារអាមេរិក

(រៀលក្នុងមួយដុល្លារអាមេរិក)

| | អត្រាប្តូរប្រាក់ប្រចាំខែ ( ចុងខែ) | | | | | |
|---|---|---|---|---|---|---|
| | អត្រាទីផ្សារ | | | អត្រាផ្លូវការ | | |
| | ទិញ | លក់ | មធ្យម | ទិញ | លក់ | មធ្យម |
| ធ្នូ-០៥ | ៤.១១៧ | ៤.១២៣ | ៤.១២០ | ៤.១១២ | ៤.១២០ | ៤.១១៦ |
| មិថុនា-០៦ | ៤.១១៨ | ៤.១២៦ | ៤.១២២ | ៤.១១០ | ៤.១១៨ | ៤.១១៤ |
| កក្កដា-០៦ | ៤.១៣៣ | ៤.១៤១ | ៤.១៣៧ | ៤.១១៤ | ៤.១២២ | ៤.១១៨ |
| សីហា-០៦ | ៤.១៧០ | ៤.១៨០ | ៤.១៧៥ | ៤.១៤៤ | ៤.១៥២ | ៤.១៤៨ |
| កញ្ញា-០៦ | ៤.១៨៨ | ៤.១៩៥ | ៤.១៩២ | ៤.១៥៤ | ៤.១៦២ | ៤.១៥៨ |
| តុលា-០៦ | ៤.១៥៣ | ៤.១៦៥ | ៤.១៥៩ | ៤.១៥០ | ៤.១៥៨ | ៤.១៥៤ |
| វិច្ឆិកា-០៦ | ៤.១០៣ | ៤.១១៣ | ៤.១០៨ | ៤.០៩៩ | ៤.១០៧ | ៤.១០៣ |
| ធ្នូ-០៦ | ៤.០៥៨ | ៤.០៧២ | ៤.០៦៥ | ៤.០៥៧ | ៤.០៦៥ | ៤.០៦១ |
| មករា-០៧ | ៤.០៦៥ | ៤.០៧៥ | ៤.០៧០ | ៤.០៦៤ | ៤.០៧២ | ៤.០៦៨ |
| កុម្ភៈ-០៧ | ៤.០៥៩ | ៤.០៦៨ | ៤.០៦៤ | ៤.០៥៧ | ៤.០៦៥ | ៤.០៦១ |
| មីនា-០៧ | ៤.០៥៧ | ៤.០៦៥ | ៤.០៦១ | ៤.០៥៥ | ៤.០៦៣ | ៤.០៥៩ |
| មេសា-០៧ | ៤.០៦៩ | ៤.០៧៧ | ៤.០៧៣ | ៤.០៦២ | ៤.០៧០ | ៤.០៦៦ |
| ឧសភា-០៧ | ៤.០៧៦ | ៤.០៨៦ | ៤.០៨១ | ៤.០៦៦ | ៤.០៧៤ | ៤.០៧០ |
| មិថុនា-០៧ | ៤.០៨៩ | ៤.០៩៩ | ៤.០៩៤ | ៤.០៧៨ | ៤.០៨៦ | ៤.០៨២ |

### ១.២.២_ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗ

ការប្រៀបធៀបអត្រាប្តូរប្រាក់រៀលជាមួយរូបិយប័ណ្ណផ្សេងៗមួយចំនួន ជាពិសេសរូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា ដោយផ្អែកលើអត្រាប្តូរប្រាក់ខ្វែងបានបង្ហាញឱ្យឃើញថា ក្នុងឆមាសទី១ ឆ្នាំ២០០៧ ប្រាក់រៀលបានចុះថ្លៃជាងប្រាក់អឺរ៉ូ ២,៩% រីងហ្គិតម៉ាឡេស៊ី ៣% ប៉េសូហ្វីលីពីន ៦,៥% និងប្រាក់បាតថៃ ១៤,៣% ។ ទន្ទឹមនឹងនេះដែរ ប្រាក់រៀលបានឡើងថ្លៃធៀបនឹងយ៉េនជប៉ុន ២,៨% ។ គួរកត់សម្គាល់ដែរថា ក្នុងអំឡុងពេលដូចគ្នានេះ ប្រាក់ដុល្លារអាមេរិកបានរងសម្ពាធចុះថ្លៃបន្តដែរ ក្នុងនោះមានជាអាទិ៍ ការចុះថ្លៃធៀបនឹង ប្រាក់អឺរ៉ូ ប្រាក់បាតថៃ ប្រាក់ដុល្លារអូស្ត្រាលី ប្រាក់យ័ន់ចិន ប្រាក់ដុល្លារសិង្ហបុរី ។ ប៉ុន្តែ ប្រាក់ដុល្លារអាមេរិកមានការឡើងថ្លៃធៀបនឹងប្រាក់យ៉េនជប៉ុន និងដុល្លារហុងកុង ។

**ក្រាហ្វិកទី ៥ : ការវិវត្តនៃតម្លៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន**




* ខ្សែគំនូសឡើងលើបង្ហាញអំពីការចុះថ្លៃនៃប្រាក់រៀល

## ២. ការវិវត្តរូបិយវត្ថុ

ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៧ នេះ ទោះបីជាបានឆ្លងកាត់នូវព្រឹត្តិការណ៍បោះឆ្នោតឃុំ-សង្កាត់ដ៏សំខាន់ក៏ដោយ ក៏ស្ថិរភាពនយោបាយនិងសន្តិសុខសង្គម គួបផ្សំនឹងនយោបាយរូបិយវត្ថុ និងសារពើពន្ធសមស្រប បានបង្កលក្ខណៈល្អប្រសើរដល់ការវិវត្តនៃចលនាអតិផរណាព្រមទាំងចលនាអត្រាប្តូរប្រាក់ ។ ទន្ទឹមនោះ កត្តាទាំងនេះក៏បាននាំមកនូវស្ថានភាពរូបិយវត្ថុមួយដ៏ប្រសើរ ដែលឆ្លុះបញ្ចាំងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលព្រមទាំងប្រព័ន្ធធនាគារទាំងមូល ។ ជាក់ស្តែង រូបិយវត្ថុទូទៅរបស់ប្រព័ន្ធធនាគារបានបន្តកើនឡើងក្នុងអត្រាកំណើនប្រហាក់ប្រហែលឆមាសទី១ ឆ្នាំមុន ហើយទ្រព្យសកម្មបរទេសសុទ្ធបានបន្តកើនឡើងក្នុងអត្រាកំណើនខ្ពស់ជាងឆមាសទី១ ឆ្នាំ២០០៦ ស្របពេលដែលទ្រព្យសកម្មក្នុងស្រុកសុទ្ធក៏បានកើនឡើងផងដែរ បើធៀបនឹងការថយចុះកាលពីឆមាសទី១ ឆ្នាំមុន ។ ការកើនឡើងនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ គឺបណ្តាលមកពីការកើនឡើងនៃឥណទានចំពោះផ្នែកឯកជន ខណៈឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលបានថយចុះគួរឱ្យកត់សម្គាល់ ។

### ២.១. ការផ្គត់ផ្គង់រូបិយវត្ថុ

រូបិយវត្ថុទូទៅរបស់ប្រព័ន្ធធនាគារក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៧នេះ បានកើនឡើងចំនួន ១.២២៧,៩ ពាន់លានរៀល (១៧,៧%) ពោលគឺកើនពី ៦.៩៤២,៣ពាន់លានរៀលក្នុងខែធ្នូ ឆ្នាំ២០០៦ ទៅ ៨.១៧០,២ពាន់លានរៀល ក្នុងខែមិថុនា ឆ្នាំ២០០៧ ។ ការកើនឡើងនៃរូបិយវត្ថុទូទៅ ជាចម្បងបណ្តាលមកពីកំណើននៃប្រាក់បញ្ញើជារូបិយប័ណ្ណរបស់និវាសជនចំនួន ១.០៧៩,៨ពាន់លានរៀល (២០,៨%) គួបផ្សំជាមួយនឹងការកើនឡើង

នៃរូបិយវត្ថុក្នុងចរាចរណ៍ចំនួន ១៣៩,១ពាន់លានរៀល (៨,៧%) ខណៈដែលប្រាក់បញ្ញើមានកាលកំណត់និងសន្សំព្រមទាំងប្រាក់បញ្ញើចរន្តជារៀលមានការកើនឡើងតិចតួចចំនួន ៦,៤ពាន់លានរៀល (៧,២%) និង ២,៥ពាន់លានរៀល (៤,៣%) រៀងគ្នា ។ កំណើននៃប្រាក់បញ្ញើជារូបិយប័ណ្ណបានឆ្លុះបញ្ចាំងនូវការកើនឡើងនៃប្រាក់បញ្ញើសន្សំចំនួន ៤២៩,២ពាន់លានរៀល (១៩,៣%) ប្រាក់បញ្ញើមានកាលកំណត់ចំនួន ៣៧២,៤ពាន់លានរៀល (២០,៥%) និងប្រាក់បញ្ញើចរន្តចំនួន ១៩១,៦ពាន់លានរៀល (១៣,៨%) ។ ប្រាក់បញ្ញើជារូបិយប័ណ្ណបានកើនឡើងជារៀងរាល់ខែក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៧ នេះ ។

### តារាងបម្រែបម្រួលជាភាគរយនៃស្ថិតិរូបិយវត្ថុសំខាន់ៗ និងសន្ទស្សន៍ថ្លៃទំនិញនិងសេវា

(បម្រែបម្រួលប្រចាំខែជាភាគរយ)

| | ធ្នូ-០៦ | មករា-០៧ | កុម្ភៈ-០៧ | មីនា-០៧ | មេសា-០៧ | ឧសភា-០៧ | មិថុនា-០៧ |
|---|---|---|---|---|---|---|---|
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | -៤,៩% | -៧,៧% | -៥,៧% | -៨,៣% | -១០១,៨% | -១០១,៨% | -១១២,៥% |
| ឥណទានចំពោះផ្នែកឯកជន | ៤,៧% | ៣,៣% | ៤,៩% | ៣,៤% | ២១,៣% | ២១,៣% | ៣៧,៥% |
| រូបិយវត្ថុទូទៅ (M2) | ៣,៨% | ៥,១% | ៤,៤% | ២,៣% | ១៦,១% | ១៦,១% | ២៩,៣% |
| រូបិយវត្ថុក្នុងចរាចរណ៍ | ៤,២% | ០,៩% | ២,៤% | ៤,៩% | ១៥% | ១៥% | ២០,១% |
| អតិផរណាប្រចាំខែ | -០,៦៥% | -០,១៦% | ០,២៦% | ០,៥៣% | ០,៨០% | ០,៤៦% | ០,២៦% |

## ២.២- កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ

ក្នុងឆមាសទី១ ឆ្នាំ២០០៧ រូបិយវត្ថុទូទៅមានកំណើន ១៧,៧% ធៀបនឹងកំណើន ២០,៣% នៃឆមាសទី១ ឆ្នាំមុន ។ ការកើនឡើងរូបិយវត្ថុទូទៅនេះគឺដោយសារកំណើននៃកត្តាគួបផ្សំទាំងពីរ គឺទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងចំនួន ១.២១១,៧ ពាន់លានរៀល (១៦,៨%) និងទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន ១៦,២ពាន់លានរៀល (៥,៧%) ។ ការកើនឡើងនៃឥណទានចំពោះផ្នែកឯកជនចំនួន ៤៦១,២ពាន់លានរៀល (១៦,៧%) គឺជាមូលហេតុតែមួយគត់នៃកំណើនទ្រព្យសកម្មក្នុងស្រុកសុទ្ធ ក្នុងឆមាសនេះ ខណៈដែលឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល និងខ្ទង់ផ្សេងៗទៀតមានការថយចុះ ។ វិស័យសំខាន់ៗដែលស្រូបយកឥណទានបន្ថែមពីប្រព័ន្ធធនាគារមាន : វិស័យសំណង់ដែលមានកំណើន ១៥៧,៣ពាន់លានរៀល (៥៨,៣%) វិស័យកម្មន្តសាល ៩៧,២ ពាន់លានរៀល (១៩៣,២%) វិស័យអចលនវត្ថុនិងការប្រើប្រាស់សាធារណៈ ៥៩,៩ពាន់លានរៀល (២០%) វិស័យសេវា ៥៤,៨ពាន់លានរៀល (៤,៨%) វិស័យលក់ដុំនិងលក់រាយ ៤៦,៨ពាន់លានរៀល (៦%) និងវិស័យកសិកម្ម ៤៤,៨ ពាន់លានរៀល (៣%) ។

### ២.២.១. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា

ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៧ បានថយចុះចំនួន ៣៥៤,០ពាន់លានរៀល (១៥,១%) ពោលគឺថយចុះពី -២.៣៤៥,៩ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៦ មក -២.៧០០ពាន់លានរៀល ក្នុងខែមិថុនា ឆ្នាំ២០០៧ នេះ បន្ទាប់ពីបានថយចុះចំនួន ៤៧៧,៨ពាន់លានរៀល (២៦,៦%) ក្នុងឆមាសទី១ ឆ្នាំ២០០៦ ។ ការថយចុះនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ គឺបណ្តាលមកពីការថយចុះនៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលចំនួន ៣៤១,១ពាន់លានរៀល (៤២,៣%) និងការថយចុះនៃផ្នែកផ្សេងៗសុទ្ធចំនួន ២៩,១ពាន់លានរៀល (២%) ។ ការថយចុះនៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល បណ្តាលមកពីការកើនឡើងប្រាក់បញ្ញើរាជរដ្ឋាភិបាលចំនួន ៣៥២,២ពាន់លានរៀល (៣២,២%) ចំណែកឥណទានចំពោះរាជរដ្ឋាភិបាលបានកើនតែ ១១,១ពាន់លានរៀល (៣,៩%) ប៉ុណ្ណោះ ។

ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៧ នេះដែរ ទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងចំនួន ៧១៤,១ពាន់លានរៀល (១២,៥%) ដែលបណ្តាលមកពីការកើនឡើងទាំងស្រុងនៃទ្រព្យសកម្មបរទេស ខណៈដែលទ្រព្យអកម្មបរទេសពុំមានការប្រែប្រួល ។ គួរកត់សម្គាល់ថា ថ្លៃមាសដែលជាធាតុផ្សំមួយនៃទ្រព្យសកម្មបរទេសបានបន្តកើនយ៉ាងលឿន ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ។

### ២.២.២. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ

ក្នុងឆមាសទី១ ឆ្នាំ២០០៧ ទ្រព្យសកម្មរបស់បណ្តាធនាគារពាណិជ្ជបានកើនឡើងចំនួន ១.៣២៤,៩ពាន់លានរៀល(១៦,៦%) ក្នុងខណៈទ្រព្យអកម្មក្នុងស្រុកក្រោមរូបភាពជាប្រាក់បញ្ញើបានកើនឡើងចំនួន ១.០៨៣,៧ពាន់លានរៀល (២០,៣%) និងទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងចំនួន ៤៩៧,៦ពាន់លានរៀល (៣៣,៣%) ។

ទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន ៣០៦,៧ពាន់លានរៀល (១៥,៦%) ក្នុងឆមាសទី ១ ឆ្នាំ ២០០៧ នេះ ។ កំណើននេះជាចម្បងបណ្តាលមកពីការកើនឡើងនៃឥណទានចំពោះផ្នែកឯកជនចំនួន ៤៦១,៣ពាន់លានរៀល (១២,៧%) ចំណែកឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលបានថយចុះចំនួន ១១,៧ពាន់លានរៀល (៨%) ។ ទន្ទឹមនេះដែរ ប្រាក់បញ្ញើរបស់បណ្តាធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជាបានថយចុះចំនួន ៣០,២ពាន់លានរៀល (៣៦២,៥%) ចំណែកខ្ទង់ផ្សេងៗសុទ្ធបានថយចុះចំនួន ១១២,៥ពាន់លានរៀល (៧,៤%) ។ ប្រាក់បញ្ញើជារូបិយប័ណ្ណរបស់និវាសជន ដែលជាធាតុផ្សំចម្បងនៃទ្រព្យសកម្មក្នុងស្រុកបានកើនឡើងចំនួន ១.០៧៩,៨ពាន់លានរៀល (២០,៨%) និងប្រាក់បញ្ញើមានកាលកំណត់និងសន្សំបានកើនឡើងចំនួន ៦,៤ពាន់លានរៀល (៧,២%) ខណៈដែលប្រាក់បញ្ញើចរន្តបានថយចុះចំនួន ២,៦ពាន់លានរៀល (៦,៣%) ។

ទ្រព្យសកម្មបរទេសសុទ្ធរបស់បណ្តាធនាគារពាណិជ្ជបានកើនឡើងចំនួន៤៩៧,៦ពាន់លានរៀល (៣៣,៣%) ពោលគឺកើនពី ១.៤៩៥,៦ពាន់លានរៀល នៅខែធ្នូ ឆ្នាំ២០០៦ ទៅ ១.៩៩៣,២ពាន់លានរៀល ក្នុងខែមិថុនា ឆ្នាំ

២០០៧ ។ កំណើននេះបណ្តាលមកពីការកើនឡើងនៃទ្រព្យសកម្មបរទេសចំនួន ៥៧៧,២ពាន់លានរៀល ( ៣០% ) ខណៈដែលទ្រព្យអកម្មបរទេសបានកើនឡើងតែ ៧៥,៦ពាន់លានរៀល ( ១៨,៧% ) ប៉ុណ្ណោះ ។

## ៣- ជញ្ជីងទូទាត់

តាមទិន្នន័យប៉ាន់ស្មានដំបូងក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជា បានបង្ហាញថា សមតុល្យរួមមានអតិរេកចំនួន ១៤២,៩លានដុល្លារអាមេរិក គឺបានកើនឡើង ៥,៦លានដុល្លារ អាមេរិក បើធៀបនឹងឆមាសដូចគ្នានៃឆ្នាំ២០០៦ ។ ការកើនឡើងនេះ បណ្តាលមកពីការកើនឡើងសមតុល្យ គណនីដើមទុននិងហិរញ្ញវត្ថុ ២,៥% ខណៈដែលឱនភាពគណនីចរន្ត ( មិនរាប់បញ្ចូលបង្វែរផ្ទេរការ ) មានកំណើន ០,២% ប៉ុណ្ណោះ ។ ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ផលធៀបនៃឱនភាពគណនីចរន្ត ( មិនរាប់បញ្ចូលបង្វែរផ្ទេរការ ) និង ផលិតផលក្នុងស្រុកសរុប មានចំនួនប្រមាណ ៥,៥% ។

### ៣.១- គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្ទេរការ)

ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ គណនីចរន្តត្រូវបានប៉ាន់ស្មានថាមានឱនភាពចំនួន ២០៥,៨លានដុល្លារ អាមេរិក គឺបានកើនឡើង ០,៥លានដុល្លារអាមេរិក ( ០,២% ) ធៀបនឹងឆមាសទី ១ ឆ្នាំ២០០៦ ។ មូលហេតុគឺ បណ្តាលមកពីមានកំណើនឱនភាពជញ្ជីងពាណិជ្ជកម្មប្រមាណ ១៥,២% និងឱនភាពគណនីប្រាក់ចំណូលសុទ្ធប្រមាណ ១៨,៥% ខណៈដែលអតិរេកនៃគណនីសេវាសុទ្ធបានកើនឡើងប្រមាណ ២៦,២% ហើយគណនីបង្វែរឯកជន សុទ្ធបានកើនឡើងប្រមាណ ២០% ។

ចំពោះការនាំចេញផលិតផលក្នុងស្រុក ក្នុងឆមាសទី ១ ឆ្នាំ២០០៧ នេះ ត្រូវបានប៉ាន់ស្មានថាមានចំនួន ១.៩៩៥,៦លានដុល្លារអាមេរិក គឺបានកើនឡើង ២៥៣,៩លានដុល្លារអាមេរិក ( ១៤,៦% ) ធៀបនឹងឆមាសទី១ ឆ្នាំ កន្លងទៅ ។ កត្តារួមចំណែកយ៉ាងសំខាន់ក្នុងកំណើននេះ គឺការកើនឡើងការនាំចេញសម្លៀកបំពាក់ និងផលិតផល វាយនភ័ណ្ឌប្រមាណ ២១៧,២លានដុល្លារអាមេរិក ។ លទ្ធផលល្អប្រសើរនៃការនាំចេញសម្លៀកបំពាក់ និងផលិតផល វាយនភ័ណ្ឌក្នុងឆ្នាំនេះ ត្រូវបានទ្រទ្រង់ម្យ៉ាងដោយកំណើនតម្រូវការប្រើប្រាស់របស់អតិថិជនបរទេស និងម្យ៉ាងទៀត ដោយការអនុវត្តវិធានការគាំពាររបស់សហរដ្ឋអាមេរិកចំពោះប្រទេសចិន ។ លើសពីនេះ ប្រទេសកម្ពុជានៅបន្ត ទទួលបានការអនុគ្រោះពន្ធនាំចូលផលិតផលវាយនភ័ណ្ឌទៅកាន់សហរដ្ឋអាមេរិក និងអឺរ៉ុប ។ គួរកត់សម្គាល់ដែរថា ផលិតផលវាយនភ័ណ្ឌរបស់ប្រទេសកម្ពុជានៅមានតម្លៃទាប បើធៀបទៅនឹងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេង ទៀត ។ ក្នុងឆមាសទី១ នេះ ការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌមានសមាមាត្រ ៧១,៨% នៃការ នាំចេញផលិតផលក្នុងស្រុក ។ ទន្ទឹមនឹងនេះ ការនាំចេញផលិតផលក្នុងស្រុកផ្សេងទៀតបានកើនឡើង ៣៦,៨លាន ដុល្លារអាមេរិក ( ៧% ) ក្នុងនោះរួមមាន ការកើនឡើងនៃការនាំចេញផលិតផលស្រូវ ត្រី គ្រឿងសង្ហារឹម និងផលិត ផលកសិកម្មផ្សេងៗទៀត ។




តម្លៃនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកត្រូវបានប៉ាន់ស្មានថាមានចំនួន ២.៥៤៩,២លានដុល្លារអាមេរិក គឺបានកើនឡើង ៣២៨,០លានដុល្លារអាមេរិក (១៤,៨%) ធៀបនឹងឆមាសដូចគ្នានៃឆ្នាំកន្លងទៅ ។ កត្តាចម្បងរួមចំណែកក្នុងការកើនឡើងនេះ គឺការនាំចូលប្រេងឥន្ធនៈបានកើនឡើង ៥៦,៥លានដុល្លារអាមេរិក (៩,៧%) ធៀបនឹង ៦ខែដូចគ្នានៃឆ្នាំ២០០៦ ដែលក្នុងនោះ បរិមាណនាំចូលត្រូវបានប៉ាន់ស្មានថា មានកំណើន ៥,៥% ខណៈដែលថ្លៃប្រេងនៅទីផ្សារអន្តរជាតិគិតជាមធ្យមបានថយចុះប្រមាណ ៥% ។ តម្លៃនៃការនាំចូលប្រេងឥន្ធនៈមានសមាមាត្រ ២៥,១% នៃការនាំចូលទំនិញប្រើប្រាស់ក្នុងស្រុក ។ ចំណែកការនាំចូលទំនិញប្រើប្រាស់ក្នុងស្រុកផ្សេងទៀត ដូចជា ការនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់មានកំណើន ១៧,៩% ហើយការនាំចូលទំនិញផ្សេងៗ មានកំណើន ១៥,៩% ។

ក្នុងអំឡុងពេលដដែលនេះ អតិរេកនៃគណនីសេវាសុទ្ធបានកើនឡើងដល់ ៣២០,៨លានដុល្លារអាមេរិក ពោលគឺបានកើនឡើង ៦៦,៦លានដុល្លារអាមេរិក (២៦,២%) ធៀបនឹងឆមាសដូចគ្នានៃឆ្នាំមុន ។ ការកើនឡើងនៃអតិរេកនេះ ជាលទ្ធផលនៃកំណើនប្រាក់ចំណូលពីផ្នែកសេវាច្រើនលើសកំណើននៃចំណាយទូទាត់សេវាដែលផ្តល់ដោយអនិវាសជន ។ ចំណូលពីសេវាទេសចរណ៍ និងសេវាដឹកជញ្ជូន បានរួមចំណែកយ៉ាងសំខាន់ក្នុងកំណើនប្រាក់ចំណូលនេះ ។ ការកែទម្រង់សេវាសាធារណៈ និងស្ថានភាពនយោបាយក្នុងប្រទេសមានភាពល្អប្រសើរ បានធ្វើឱ្យចំនួនភ្ញៀវបរទេសដែលបានចូលមកទស្សនាប្រទេសកម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ មានការកើនឡើងដល់ប្រមាណ ៩៨៥.៧៥២នាក់ ដែលចំនួននេះមានត្រឹមតែ ៨១៣.៣៩២នាក់ ក្នុងឆមាសទី១ ឆ្នាំ២០០៦ ។ ចំពោះគណនីប្រាក់ចំណូលសុទ្ធត្រូវបានប៉ាន់ស្មានថា មានឱនភាពចំនួន ១៦០,៨លានដុល្លារអាមេរិក គឺមានកំណើន ២៥,១ លានដុល្លារអាមេរិក (១៨,៥%) ធៀបនឹង ៦ខែ ដើមឆ្នាំ២០០៦ ។ ការកើនឡើងនៃឱនភាពនេះគឺដោយសារ

កំណើននៃការផ្ទេរចេញទៅឱ្យអនិវាសជន ដែលបានកើនលើសកំណើននៃប្រាក់ចំណូលដែលទទួលបានពីបរទេស ។ ចំណែកអតិរេកនៃគណនីបង្វែរឯកជនសុទ្ធបានកើន ២៩,៣លានដុល្លារអាមេរិក (២០%) ក្នុងនោះ មួយផ្នែកធំគឺ ដោយសារកំណើនប្រាក់បង្វែររបស់ជនជាតិកម្ពុជាដែលធ្វើការនៅក្រៅប្រទេស ។

## ៣.២. គណនីដើមទុន និងហិរញ្ញវត្ថុ

ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ សមតុល្យគណនីចរន្ត និងបង្វែរដើមទុនមានអតិរេក ២,២លានដុល្លារ អាមេរិក ធៀបនឹងអតិរេក ៩៧,៥លានដុល្លារអាមេរិក ក្នុងឆមាសដូចគ្នានៃឆ្នាំ២០០៦ ។ លំហូរបង្វែរផ្លូវការសុទ្ធត្រូវ បានប៉ាន់ស្មានថាមានចំនួន ២០៨លានដុល្លារអាមេរិក គឺបានថយចុះ ៥៤,៨លានដុល្លារអាមេរិក ស្មើ ២០,៩% ធៀបនឹង លំហូរចូលក្នុងឆមាសទី១ ឆ្នាំ២០០៦ ។ គណនីនេះបង្ហាញពីលំហូរហិរញ្ញប្បទានសហប្រតិបត្តិការ ដែលរាជរដ្ឋាភិបាល កម្ពុជាទទួលបានពីសហគមន៍អន្តរជាតិទាំងពហុភាគីនិងទ្វេភាគី ក្នុងនោះរួមមាន ហិរញ្ញប្បទានសម្រាប់ទ្រទ្រង់ថវិកា ១០,៦លានដុល្លារអាមេរិក ហិរញ្ញប្បទានសម្រាប់ស្បៀងអាហារ ១៤,៧លានដុល្លារអាមេរិក ហិរញ្ញប្បទានសម្រាប់ គម្រោង ៩៣,៣លានដុល្លារអាមេរិក និងហិរញ្ញប្បទានសម្រាប់ជំនួយបច្ចេកទេស ៨៩,៥លានដុល្លារអាមេរិក ។ ទន្ទឹម នឹងនេះ លំហូរជំនួយជាប្រាក់កម្ចីផ្លូវការសុទ្ធ (មិនរាប់បញ្ចូលប្រាក់កម្ចីពីមូលនិធិរូបិយវត្ថុអន្តរជាតិ) ត្រូវបានប៉ាន់ស្មាន ថាមានចំនួន ៣៩លានដុល្លារអាមេរិក គឺបានថយចុះ ២៨,២% ធៀបនឹងឆមាសទី១ ឆ្នាំ២០០៦ ។ ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ លំហូរវិនិយោគផ្ទាល់បរទេសសុទ្ធត្រូវបានប៉ាន់ស្មានថាមានចំនួន ២៤៧,៧លានដុល្លារអាមេរិក ក្នុងនោះលំហូរវិនិយោគផ្ទាល់បរទេសផ្នែកសហគ្រាសចំនួន ២១២,៤លានដុល្លារអាមេរិក ។ លំហូរវិនិយោគផ្ទាល់ បរទេសផ្នែកសហគ្រាសនេះ បានឆ្លុះបញ្ចាំងនូវកំណើនគម្រោងវិនិយោគផ្នែកកាត់ដេរសម្លៀកបំពាក់ និងទំនិញ វាយនភ័ណ្ឌ ផ្នែកទូរគមនាគមន៍ ផ្នែកវេចខ្ចប់ ផ្នែកសំណង់ ផ្នែកមន្ទីរពេទ្យ និងផ្នែកអភិវឌ្ឍដីកសិកម្ម ។



ការកើនឡើងនៃគណនីដើមទុននិងហិរញ្ញវត្ថុ បានបង្ហាញពីលទ្ធភាពទ្រទ្រង់បានដើម្បីផាត់ទាត់ឱ្យឱនភាពគណនីចរន្តទាំងស្រុង ។ ជាលទ្ធផលនៃប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ សមតុល្យរួមមានអតិរេក ១៤២,៩លានដុល្លារអាមេរិក ។ គិតដល់ខែមិថុនា ឆ្នាំ២០០៧ ទុនបម្រុងអន្តរជាតិដុល អាចធានាឱ្យការទូទាត់ទំនិញនាំចូលបានប្រមាណ ៣ខែ ។

## ៤-ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

### ៤-១-ការងារវិនិយោគទុនបម្រុងអន្តរជាតិ

ទុនបម្រុងអន្តរជាតិដុលជារូបិយប័ណ្ណនៅបរទេសត្រូវបានធ្វើវិនិយោគដោយប្រុងប្រយ័ត្នក្រោមរូបភាពជា Overnight ជាការទិញប័ណ្ណរតនាគារអាមេរិក ជាប្រាក់បញ្ញើរយៈកាលខ្លី ជាឧបករណ៍រយៈកាលមធ្យម (MTI) និងជាសញ្ញាប័ណ្ណរយៈកាលវែង នៅប្រទេសបារាំង លុចហ្សំបួរ ស្វីស សហរដ្ឋអាមេរិក ហុងកុង និងសិង្ហបុរី ។ គិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០០៧ ទុនបម្រុងអន្តរជាតិដុលគិតជាប្រាក់ដុល្លារអាមេរិក (ដោយមិនរាប់បញ្ចូលមាស និង SDR) មានចំនួនសរុប ១,៣ពាន់លានដុល្លារអាមេរិក គឺកើនឡើង ១៥% បើប្រៀបធៀបនឹងចុងខែធ្នូ ឆ្នាំ២០០៦ ដែលមានចំនួន ១,១២ ពាន់លានដុល្លារអាមេរិក និងកើនឡើង ៣០,៥៦% បើធៀបចុងឆមាសទី១ ឆ្នាំ២០០៦ ។

នៅក្នុងឆមាសទី១ ឆ្នាំ២០០៧ អត្រាការប្រាក់ដុល្លារអាមេរិកត្រូវបានរក្សានៅកម្រិតដដែល ៥,២៥% អត្រាការប្រាក់អឺរ៉ូបានកើនពី ៣,៥០% ទៅ ៤% អត្រាការប្រាក់ផោនបានកើនពី ៥,២៥%ទៅ ៥,៥០% រីឯអត្រាការប្រាក់ដុល្លារអូស្ត្រាលីនៅរក្សាស្ថានភាពដដែល ៦,២៥% ។ កត្តានេះបណ្តាលឱ្យអត្រាការប្រាក់ Overnight ប្រែប្រួលពី ៤,៨១% ទៅ ៥,២៦% អត្រាការប្រាក់ប័ណ្ណរតនាគារអាមេរិកប្រែប្រួលពី ៥,០៦២% ទៅ ៥,១៦៤% អត្រាការប្រាក់បញ្ញើរយៈកាលខ្លីជាប្រាក់ដុល្លារអាមេរិកប្រែប្រួលពី ៥,០៧% ទៅ ៥,៣១% អត្រាការប្រាក់អឺរ៉ូប្រែប្រួលពី ៣,៤៦% ទៅ ៣,៨៣% អត្រាការប្រាក់ផោនប្រែប្រួលពី ៥,៣២% ទៅ ៥,៥៦% និងអត្រាការប្រាក់ដុល្លារអូស្ត្រាលីប្រែប្រួលក្នុងរង្វង់ ៦,១៨% ។ ប្រការនេះ បានធ្វើឱ្យការវិនិយោគទទួលបានលទ្ធផលល្អប្រសើរ បើធៀបនឹងរយៈពេលដូចគ្នានៃឆមាសទី១ ឆ្នាំ២០០៦ កន្លងមក ។ ជាក់ស្តែង ចំណូលនៅក្នុងឆមាសទី១ ឆ្នាំ២០០៧ មានចំនួន ៣០,៧៦លានដុល្លារអាមេរិក រីឯលទ្ធផលឆមាសទី១ ឆ្នាំ២០០៦ ទទួលបានតែ ២១,២៥លានដុល្លារអាមេរិកប៉ុណ្ណោះ ពោលគឺបានកើនឡើងប្រមាណ ៤៤,៧% ។

### ៤.២- អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់

នៅក្នុងឆមាសទី១ ឆ្នាំ២០០៧ ដោយសារស្ថានភាពអត្រាប្តូរប្រាក់នៅលើទីផ្សារមានស្ថិរភាពល្អ គួបផ្សំនឹងស្ថានភាពសេដ្ឋកិច្ចអំណោយផល ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកបានចំនួន ៥៦លើក ដែលមានចំនួនប្រាក់សរុប ៩៥,២លានដុល្លារអាមេរិក ដោយចំណាយប្រាក់រៀលអស់ចំនួន ៣៨៦,៨ពាន់លានរៀល ។

ដោយឡែក នៅចុងខែឧសភា ឆ្នាំ២០០៧ ដោយមានសម្ពាធបន្តិចបន្តួចមកលើប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដេញថ្លៃប្រាក់ដុល្លារចំនួន ៣លានដុល្លារអាមេរិក តែការដេញថ្លៃនេះសម្រេចបានតែចំនួន ៥០០ ពាន់ដុល្លារអាមេរិកតែប៉ុណ្ណោះ ហើយប្រាក់រៀលហាក់ដូចជាមានលំនឹងឡើងវិញ ។

### ៤.៣- ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់

ក្នុងឆមាសទី១ ឆ្នាំ២០០៧ ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់មាស និងប្តូរប្រាក់នៅរាជធានីភ្នំពេញមានចំនួនសរុប ១២៦ច្បាប់ ក្នុងនោះអាជីវកម្មប្តូរប្រាក់មានចំនួន ២៣ច្បាប់ ។រីឯនៅតាមខេត្ត-ក្រុង ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់មាស និងប្តូរប្រាក់មានចំនួនសរុប ៣.២៥២ច្បាប់ ក្នុងនោះមាន អាជីវកម្មប្តូរប្រាក់ចំនួន ៤៤៩ច្បាប់ និងអាជីវកម្មលក់មាសចំនួន ២.៨០៣ច្បាប់ ។

## ៥- សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

### ៥.១- ការត្រួតពិនិត្យធនាគារពាណិជ្ជ និងធនាគារឯកទេស

ធនាគារជាតិនៃកម្ពុជា នៅតែបន្តការបណ្តុះបណ្តាល កសាង និងអភិវឌ្ឍសមត្ថភាពដល់មន្ត្រីបុគ្គលិក ដើម្បីបង្កើនប្រសិទ្ធភាពធនធានមនុស្សក្នុងការអនុវត្តការងារ ទាំងការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែងលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងការពិនិត្យតាមដានការអនុវត្តប្រកាស បទបញ្ជា សារាចរ-ណែនាំ ដែលបានចេញផ្សាយផងដែរ ។

#### ៥.១.១- ការត្រួតពិនិត្យលើឯកសារ

នៅក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ស្ថានភាពហិរញ្ញវត្ថុរបស់បណ្តាគ្រឹះស្ថានធនាគារកំពុងដំណើរការប្រកបដោយប្រសិទ្ធភាព ។ សកម្មភាពប្រតិបត្តិការរបស់ធនាគារត្រូវបានត្រួតពិនិត្យជាប្រចាំ ដើម្បីពិនិត្យលើការអនុវត្តច្បាប់ បទប្បញ្ញត្តិប្រុងប្រយ័ត្ន និងស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ។ សកម្មភាពរបស់គ្រឹះស្ថានធនាគារភាគច្រើនទទួលបានលទ្ធផលល្អ ទាំងលទ្ធភាពរកចំណេញ ការគោរពច្បាប់ និងបទប្បញ្ញត្តិប្រុងប្រយ័ត្នផ្សេងៗរបស់ធនាគារជាតិនៃកម្ពុជា ។ ការផ្តល់ឥណទាន និងការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារមានការកើនឡើងជាលំដាប់ ដែលបញ្ជាក់ឱ្យឃើញពីជំនឿទុកចិត្តរបស់សាធារណជនចំពោះប្រព័ន្ធធនាគារនៅកម្ពុជា ។

ក្នុងគោលបំណងធ្វើឱ្យការត្រួតពិនិត្យលើឯកសារកាន់តែស៊ីជម្រៅ និងមានប្រសិទ្ធភាពសម្រាប់ការវិភាគ វាយតម្លៃស្ថានភាពធនាគារឱ្យកាន់តែសុក្រឹត កម្មវិធីកុំព្យូទ័រកូប្រា (Cambodian Offsite Bank Reporting for prompt corrective Action ) ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងជាបណ្តើរៗ ។ លទ្ធផលជាដំបូង បានបង្ហាញថា កម្មវិធីនេះមានប្រសិទ្ធភាពជាងការធ្វើដោយដៃជាច្រើន ដោយធ្វើឱ្យការងាររឆាប់រហ័ស និងជួយដល់ការវិភាគបាន

ត្រឹមត្រូវជាងមុន ។ ដូច្នេះ កម្មវិធីនេះនឹងត្រូវអនុវត្តឱ្យបានពេញលេញ និងកែលំអឱ្យកាន់តែប្រសើរឡើងនៅពេលអនាគតដ៏ខ្លី ។

### ៥.១.២. ការត្រួតពិនិត្យដល់ទីកន្លែង

ការងារត្រួតពិនិត្យដល់ទីកន្លែង ជាការងារដ៏សំខាន់មួយទៀតសម្រាប់បំពេញឱ្យការងារត្រួតពិនិត្យលើឯកសារ និងបង្ហាញឱ្យឃើញពីដំណើរការរបស់ធនាគារយ៉ាងច្បាស់លាស់ ។ ឆ្នាំ២០០៧ ធនាគារជាតិនៃកម្ពុជាបានសម្រេចដាក់ចេញនូវផែនការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជចំនួន ១៥ ក្នុងនោះមានសាខាធនាគារបរទេស ៣ និងធនាគារឯកទេស ៥ ព្រមទាំងសាខាដែលស្ថិតនៅតាមបណ្តាខេត្ត ។

ក្នុងឆមាសទី១ នេះ ការត្រួតពិនិត្យដល់ទីកន្លែងតាមវិសាលភាពពេញលេញលើធនាគារពាណិជ្ជចំនួន ៥ ក្នុងនោះ សាខាបរទេស ១ និងធនាគារឯកទេស ១ ត្រូវបានបញ្ចប់ជាស្ថាពរ ។ ការត្រួតពិនិត្យដល់ទីកន្លែងនេះមានទិសដៅ និងគោលបំណងធ្វើការតាមដាន និងពិនិត្យរាល់ប្រតិបត្តិការអាជីវកម្មធនាគារពាណិជ្ជ និងធនាគារឯកទេសឱ្យបានស៊ីជម្រៅ ព្រមទាំងវាយតម្លៃពីភាពពិតប្រាកដ និងត្រឹមត្រូវជាក់លាក់នៃរបាយការណ៍ និងស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានទាំងនោះ ។ ជាពិសេស ការត្រួតពិនិត្យដល់ទីកន្លែងនេះបានយកចិត្តទុកដាក់ពិនិត្យលើការអនុវត្តរបស់គ្រឹះស្ថានទាំងនោះទៅតាមច្បាប់ ប្រកាស សារាចរណែនាំ បទប្បញ្ញត្តិប្រុងប្រយ័ត្ន ដើម្បីកាត់បន្ថយនិងបញ្ចៀសហានិភ័យនានាដែលអាចកើតមានចំពោះធនាគារ ។ បញ្ហាដែលត្រូវបានរកឃើញក្នុងការត្រួតពិនិត្យនេះគឺធនាគារ មួយចំនួនតូចធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធនមិនទាន់បានត្រឹមត្រូវតាមប្រកាសទាំងស្រុងនៅឡើយ ។ រាល់ចំណុចខ្វះខាត និងកំហុសឆ្គងដែលបានរកឃើញ ក្នុងពេលត្រួតពិនិត្យ ត្រូវបានផ្តល់ជាអនុសាសន៍ និងដាក់ចេញជាវិធានការចាំបាច់ដើម្បីឱ្យសាមីធនាគារធ្វើការកែតម្រូវ ជាបន្តបន្ទាប់ ។

## ៥.២. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ក្នុងឆមាសទី១ ឆ្នាំ២០០៧ ឥណទានសរុបដែលបានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទប្រមាណ ៤៧៩ពាន់លានរៀល កើនឡើង ២៨% និងចំនួនអ្នកខ្ចីប្រាក់មានប្រមាណ ៥៤៨.០២៥ នាក់ កើនឡើង ១៦% បើប្រៀបធៀបនឹងខែធ្នូ ឆ្នាំ២០០៦ ។ នេះបង្ហាញឱ្យឃើញពីកំណើនក្នុងវិស័យហិរញ្ញវត្ថុជនបទ ។

នៅក្នុងគ្រាដូចគ្នានេះដែរ ការកេណ្ឌប្រមូលប្រាក់សន្សំទាំងផ្នែកសន្សំដោយកាតព្វកិច្ច និងសន្សំដោយស្ម័គ្រចិត្តមានប្រមាណ ១៧,៥ពាន់លានរៀល កើនឡើង ៤៧% ដោយមានអតិថិជនផ្ញើប្រាក់ចំនួនប្រមាណ ២០៥.៥០១ នាក់ កើនឡើង ៨១% បើប្រៀបធៀបនឹងខែធ្នូ ឆ្នាំ២០០៦ ។ ការកើនឡើងនៃប្រាក់សន្សំនេះ ឆ្លុះបញ្ចាំងឱ្យឃើញពីទំនុកចិត្តរបស់អ្នកសន្សំប្រាក់ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលត្រូវបានចុះត្រួតពិនិត្យដល់ទីកន្លែងមាន ៣ គឺ ក្រេឌិត ប្រាសាក់ និងធនាគារភូមិ ។ ក្នុងឆមាសទី១ នេះ អង្គការសមាគមដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីជាប្រតិបត្តិករឥណទានជនបទ និងចុះបញ្ជីមានចំនួន ៨ រួមមាន : អង្គការហ្វីសហូមភីអិលស៊ី បណ្តាញអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ អង្គការស៊ីអាយស៊ីអេមកម្ពុជា អង្គការអភិវឌ្ឍន៍សង្គមជនបទ សហព័ន្ធសហគមន៍សន្សំប្រាក់កម្ពុជា សមាគមអភិវឌ្ឍន៍ស្រុកស្រែ អង្គការឥស្លាមអភិវឌ្ឍន៍ជនបទ និងអង្គការអភិវឌ្ឍន៍ជនបទខ្មែរ ។

ការចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអង្គការ សមាគម ជាទូទៅបានបង្ហាញពីស្ថានភាពមធ្យម ។ បញ្ហាប្រឈមមួយចំនួនដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជួបប្រទះមានដូចជា ការខ្វះខាតប្រភពទុនសម្រាប់ពង្រីកប្រតិបត្តិការ ខ្វះមន្ត្រីមានសមត្ថភាព និងភាពស្មោះត្រង់របស់មន្ត្រី-បុគ្គលិក ហេដ្ឋារចនាសម្ព័ន្ធសង្គម និងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរដែនដីជាដើម ។

### ៥.៣. ការជម្រះបញ្ជីធនាគារ

នៅក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាបានប្រមូលបំណុល និងរឹបអូសអចលនទ្រព្យលក់ឡៃឡុងរបស់ធនាគារក្រៅប្រទេសទី ១ ចំកាត់ ទទួលបានលទ្ធផលល្អប្រសើរ ហើយសង្ឃឹមថាអាចទូទាត់សងអតិថិជនបានគ្រប់ចំនួននៅពេលឆាប់ៗ ខាងមុខនេះ ។

### ៥.៤. ការងាររៀបចំបទបញ្ញា

ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ប្រកាស បទប្បញ្ញត្តិ បទបញ្ជា និងសារាចរណែនាំ ដែលបានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តកន្លងមក ត្រូវបានពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ដើម្បីឆ្លើយតបបានតាមការវិវត្តនៃវិស័យហិរញ្ញវត្ថុ ។ ជាលទ្ធផល ប្រកាសចំនួន ២ ត្រូវបានធ្វើវិសោធនកម្ម និងប្រកាសចំនួន ២ ត្រូវបានរៀបចំថ្មី រួមមាន:

- ប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារ
- ប្រកាសស្តីពី ស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ប្រកាសស្តីពី អនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

### ៥.៥. អាជ្ញាប័ណ្ណ និងការចុះបញ្ជី

ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ធនាគារពាណិជ្ជដែលបានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មធនាគារ រួមមាន ធនាគារខេមខូលីមីតធីត និងធនាគាឯកទេស ខេមបូឌានឌីវឺឡុបមែន ។

អាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលពីមុនមកត្រូវបានកំណត់សុពលភាពរយៈពេល ៣ឆ្នាំ ត្រូវបានប្តូរទៅជាអាជ្ញាប័ណ្ណមិនមានកាលកំណត់រយៈពេលសុពលភាព ។ រហូតដល់បច្ចុប្បន្ននេះ ប្រព័ន្ធធនាគាររួមមាន ធនាគារពាណិជ្ជចំនួន ១៦ ធនាគារឯកទេសចំនួន ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១៧ និងប្រតិបត្តិករឥណទានដែលមានវិញ្ញាបនប័ត្រចំនួន ២៦ ។

### ៥.៦- ចំណូលពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងស្នងការគណនី

ចំណូលពីសោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំដែលធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្នងការគណនី សោហ៊ុយផ្តល់ព័ត៌មានសុំបើកធនាគារ និងសិក្សាសំណុំលិខិតប្រាក់ពិន័យផ្សេងៗ ការធ្វើវិសោធនកម្ម លើអនុស្សារណៈ និងលក្ខន្តិកៈមានចំនួន ៤,៣៦ពាន់លានរៀល និង ៦៥ពាន់ដុល្លារអាមេរិក នៅដំណាច់ឆមាស ទី១ ឆ្នាំ២០០៧ ។

## ៦- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល

### ៦.១- សេវាផ្នែកគណនី

ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងគណនីស្ថាប័នរដ្ឋ អង្គការរដ្ឋបាលកណ្តាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ។ សរុបគណនីទាំងអស់មានចំនួន ១.១៣៣គណនី ដែលជារូបិយវត្ថុជាតិ និងរូបិយប័ណ្ណដុល្លារអាមេរិក ។ ប្រតិបត្តិការសរុបក្នុងឆមាសទី១ ឆ្នាំ២០០៧ មានចំនួន ៩៤.៨០០ប្រតិបត្តិការ ពោលគឺមានការថយចុះ ៣% បើធៀបទៅនឹងឆមាសទី១ ឆ្នាំ២០០៦ ដែលមានចំនួន ៩៨.៥៩៩ប្រតិបត្តិការ ។ ការថយចុះនៃប្រតិបត្តិការនេះ បណ្តាលមកពីការចែករំលែកប្រតិបត្តិការមួយចំនួនទៅឱ្យសាខាធនាគារក្រុងដែលទើបបើកដំណើរការឡើងវិញ ។

#### ៦.១.១- សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ

ធនាគារជាតិនៃកម្ពុជាក៏បានរួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនប្រសិទ្ធភាពកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយទទួលបើកគណនីជូនស្ថាប័នរដ្ឋបាលកណ្តាល គ្រប់គ្រង និងចាត់សម្រួលសាច់ប្រាក់តាមរយៈការបង្វែរប្រាក់រតនាគារជាតិ និងបើកប្រាក់បៀវត្សជូនមន្ទីរ-ក្រសួង និងកងកម្លាំងប្រដាប់អាវុធ ។

ការបង់ពន្ធដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជាពីសំណាក់អ្នកជាប់ពន្ធ បានប្រព្រឹត្តទៅដោយរលូនមានបរិមាណ ៧៩២,៩ពាន់លានរៀល ( គិតទាំងចំណូលជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក) ។

### ៦.១.២. ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរដ្ឋាភិបាល

#### ៦.១.២.១. ហិរញ្ញប្បទាន និងកម្ចីរបស់រាជរដ្ឋាភិបាលជប៉ុន

##### ក. ហិរញ្ញប្បទានឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន

##### ក.១. ហិរញ្ញប្បទានឥតសំណងក្នុងគម្រោង

ក្នុងឆមាសទី១ ឆ្នាំ២០០៧ រដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងបន្ថែមដល់រាជរដ្ឋាភិបាលកម្ពុជាចំនួន ១ គម្រោងទៀត គឺគម្រោងរៀបចំប្រព័ន្ធលូបង្ហូរទឹកនៅទីក្រុងភ្នំពេញដែលមានចំនួនប្រាក់ ៤៩លានយ៉េន ។ ចំពោះគម្រោងកែលំអបរិក្ខារសន្តិសុខ និងសម្ភារៈនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលមានចំនួនប្រាក់សរុប ៩២៧លានយ៉េន ធនាគារជាតិនៃកម្ពុជាបានចេញ Authorization to Pay សម្រាប់ទូទាត់ ១លើក ដែលមានចំនួនប្រាក់ ៥៩,៨លានយ៉េន ។ គម្រោងនេះនៅមានសមតុល្យចំនួន ៨៦៧,២លានយ៉េន ។ រីឯគម្រោងផ្គត់ផ្គង់ទឹកស្អាតតំបន់ដាច់ស្រយាលខេត្តកំពង់ចាមមានចំនួនប្រាក់ ៤៣១លានយ៉េន ដោយធនាគារជាតិនៃកម្ពុជាបានចេញ Authorization to Pay សម្រាប់ទូទាត់ ១លើកថែមទៀត មានចំនួនប្រាក់ ២១៨លានយ៉េន ហើយគម្រោងនេះនៅមានសមតុល្យ ១៤៥,៦លានយ៉េន ។ ទន្ទឹមនេះ មានគម្រោងផ្សេងៗទៀតដែលកំពុងត្រូវបានអនុវត្តជាបន្តបន្ទាប់និងមិនទាន់ចប់នៅឡើយ ដូចជា :

- គម្រោងពង្រីកផ្លូវជាតិលេខ ១ (ROAD 0608) អនុវត្តរហូតដល់ខែមីនា ឆ្នាំ២០០៩
- គម្រោងធ្វើការសិក្សាវិស្វកម្មលំអិតវារីអគ្គិសនីធុនតូចសម្រាប់អគ្គិសនីភាវូបនីយកម្មនៅជនបទដាច់ស្រយាល ខេត្តមណ្ឌលគិរី (ELECTRIFICATION 0607) អនុវត្តរហូតដល់ខែមីនា ឆ្នាំ ២០០៨
- គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស (SCHOLARSHIP 0609) អនុវត្តរហូតដល់ខែ មីនា ឆ្នាំ២០១០
- គម្រោងស្តារប្រព័ន្ធធារាសាស្ត្រស្រុកកណ្តាលស្ទឹង (IRRIGATION 0507) អនុវត្តរហូតដល់ខែ សីហា ឆ្នាំ២០០៧ និង
- គម្រោងស្តារស្ពានសំខាន់ៗ (ROAD 0507) អនុវត្តរហូតដល់ខែមីនា ឆ្នាំ២០០៨ ។

##### ក.២. ហិរញ្ញប្បទានឥតសំណងក្រៅគម្រោង

ក្នុងឆមាសទី១ ឆ្នាំ២០០៧ រាជរដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងក្រៅគម្រោងដល់រាជរដ្ឋា-ភិបាលកម្ពុជាចំនួន ១២០០លានយ៉េន សម្រាប់ជួយសម្រាលផ្នែកសេដ្ឋកិច្ច ។ ចំពោះការទូទាត់ហិរញ្ញប្បទាន

នេះ ធនាគារ Bank of Tokyo-Mitsubishi UFJ Ltd បានផ្ទេរប្រាក់នេះចូលក្នុងគណនីរបស់ Japan International Cooperation System (JICS) រួចហើយ ។

### ខ. កម្ចីសម្បទានរបស់រដ្ឋាភិបាលជប៉ុន

ក្នុងឆមាសទី១ នេះ កម្ចីសម្បទានសម្រាប់អភិវឌ្ឍន៍កំពង់ផែក្រុងព្រះសីហនុ Loan No CP-P4 (ឆ្នាំ២០០៥) ចំនួន ៤.៣១៣លានយ៉េន ត្រូវបានដកប្រើប្រាស់អស់ចំនួន ១.១៣០,២លានយ៉េន ។ រីឯកម្ចីសម្ប-ទានសម្រាប់អភិវឌ្ឍន៍កំពង់ផែក្រុងព្រះសីហនុ Loan No CP-P6 (ឆ្នាំ២០០៦) ចំនួន ៣១៨លានយ៉េន មិនទាន់បានដកប្រើប្រាស់ទេ ។ ទន្ទឹមនឹងនេះ គម្រោង Greater Mekong Telecommunication Backbone Network Project (Loan No. CP-P5) ដែលបានចុះកិច្ចព្រមព្រៀងកាលពីឆ្នាំ២០០៥ មានចំនួន ៣.០២៩លានយ៉េន ក៏ពុំទាន់បានប្រើប្រាស់នៅឡើយ (ផ្អែកតាមតួលេខពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។

### ៦.១.៣. សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

គណនីដែលធនាគារពាណិជ្ជបានបើកនៅធនាគារជាតិនៃកម្ពុជារួមមាន គណនីចរន្ត គណនីប្រាក់បញ្ញើមានកាលកំណត់ គណនីប្រាក់បញ្ញើធានាលើដើមទុន និងគណនីប្រាក់បម្រុងកាតព្វកិច្ច ។ ប្រាក់បញ្ញើមានកាលកំណត់រយៈពេល ១ខែ ៣ខែ ៦ខែ មានចំនួនប្រាក់សរុប ២៤០លានដុល្លារអាមេរិក ។

## ៦.២. សេវាផាត់ទាត់

ប្រតិបត្តិការទូទាត់តាមរយៈសភាផាត់ទាត់បានដំណើរការប្រកបដោយប្រសិទ្ធភាព និងមានប្រតិបត្តិការជារៀងរាល់ថ្ងៃធ្វើការ ទាំងការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀលនិងជាប្រាក់ដុល្លារអាមេរិក ។

ការប្រើប្រាស់មូលប្បទានប័ត្រមាននិន្នាការរីកចម្រើនជាបណ្តើរៗ ជាពិសេសក្នុងមជ្ឈដ្ឋានធនាគារពាណិជ្ជ និងអង្គភាពរដ្ឋ ។ ការកំណត់ឱ្យប្រើមូលប្បទានប័ត្រដើម្បីបង់ពន្ធគ្រប់ប្រភេទ បានធ្វើឱ្យចំនួននៃការប្រើប្រាស់មូលប្បទានប័ត្រមានការកើនឡើង ។

### ៦.២.១. ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល

សភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់រៀលមានសមាជិកចំនួន ១៦ ដែលរួមមាន ធនាគារពាណិជ្ជចំនួន ១៣ រតនាគារជាតិ ធនាគារឯកទេស ១ និងធនាគារជាតិនៃកម្ពុជា ។

ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀលបានដំណើរការចំនួន ១២០ ថ្ងៃ មានមូលប្បទានប័ត្រចំនួន ១០.៨៨០សន្លឹក ដែលមានប្រាក់សរុបចំនួន ៣៨១,៧ពាន់លានរៀល ។ សកម្មភាព

ផាត់ទាត់ក្នុងឆមាសទី១ នេះ មានការកើនឡើងបន្តិចនូវចំនួនមូលប្បទានប័ត្រ ប៉ុន្តែចំនួនប្រាក់មានការថយចុះបន្តិចវិញ បើធៀបទៅនឹងឆមាសទី២ ឆ្នាំ២០០៦ កន្លងមកនេះ ពោលគឺកើនពី ១០.៦៨៤សន្លឹក ទៅ ១០.៨៨០សន្លឹក (២%) និងចំនួនប្រាក់ថយចុះពី ៣៨៤,៣ពាន់លានរៀល មក ៣៨១,៧ពាន់លានរៀល (១%) ។

### ៦.២.២. ការផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់ដុល្លារអាមេរិក

សភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិកមានសមាជិកចំនួន ១៩ ដែលជាធនាគារពាណិជ្ជចំនួន ១៥ ធនាគារឯកទេស ៣ និងធនាគារជាតិនៃកម្ពុជា ។

សកម្មភាពនៃការផាត់ទាត់ក្នុងឆមាសទី១ ឆ្នាំ២០០៧ បានដំណើរការចំនួន ១២០ថ្ងៃ ធ្វើការផាត់ទាត់លើមូលប្បទានប័ត្រចំនួន ១៤៨.០០០សន្លឹក មានចំនួនប្រាក់ ១.៩០០លានដុល្លារអាមេរិក ។ សកម្មភាពផាត់ទាត់មានការកើនឡើងបន្តិចទាំងចំនួនមូលប្បទានប័ត្រ និងចំនួនប្រាក់ បើធៀបទៅនឹងឆមាសទី២ ឆ្នាំ២០០៦ ពោលគឺចំនួនមូលប្បទានប័ត្រកើនពី ១៣៨.១៩៤សន្លឹក ទៅ ១៤៨.០០០សន្លឹក (៧%) និងចំនួនប្រាក់កើនពី ១,៥៥១លានដុល្លារអាមេរិក ទៅ ១.៩០០លានដុល្លារអាមេរិក (២៣%) ។

## ៦.៣. ការខារឥណទាន

ក្នុងឆមាសទី១ ឆ្នាំ ២០០៧ ធនាគារជាតិនៃកម្ពុជាបានផ្តល់ឥណទាន និងប្រមូលបំណុល ដូចខាងក្រោម :

- គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ : សមតុល្យដើមគ្រា ៤៣.៥ពាន់លានរៀល ឱ្យខ្ចីក្នុងគ្រា ៥៩.៥ពាន់លានរៀល ប្រមូលបំណុល៤៧.៥ពាន់លានរៀល សមតុល្យចុងគ្រា ៥៥.៥ពាន់លានរៀល
- ឥណទានចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់សងបំណុល ODA ជប៉ុន (បំណុលចាស់មុនឆ្នាំ១៩៧០) : ឱ្យខ្ចី ៤៧២.៥លានយ៉េន ប្រមូលបំណុល ៤៧.២៥លានយ៉េន សមតុល្យចុងគ្រា ៤២៥.២៥ លានយ៉េន ។

# ៧. ការគ្រប់គ្រងចរាចរណ៍ធនប័ត្រ

បច្ចុប្បន្នចរន្តលំហូរចូល-ចេញនៃសាច់ប្រាក់រៀលតាមរយៈគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឆ្លងកាត់បេឡាប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជាមានការកើនឡើងជាលំដាប់ ។ ជាក់ស្តែងក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ចំណូលសាច់ប្រាក់តាមបេឡាប្រតិបត្តិការសរុបមានចំនួន ១.៥៩៧ពាន់លានរៀល ។ បើប្រៀបធៀបនឹងគ្រាដូចគ្នានៃឆ្នាំ២០០៦ ឃើញថា កើនលើស ៩៥% ។ ក្នុងនោះ ចំណូលសាច់ប្រាក់បង់ពន្ធគ្រប់ប្រភេទបញ្ចូលក្នុងគណនីប្រាក់បញ្ញើចរន្តរបស់រតនាគារជាតិមានសមាមាត្រ ៣៨% ចំណូលសាច់ប្រាក់ពីប្រាក់បញ្ញើចរន្តនានា ៣៨% ចំណូលសាច់ប្រាក់បង់ថ្លៃអគ្គិសនីកម្ពុជា ១២% និងចំណូលសាច់ប្រាក់ផ្សេងៗទៀត ១២% ។

ចំណែកឯសាច់ប្រាក់ចំណាយតាមបេឡាប្រតិបត្តិការសរុបវិញចំនួន ១.៧២៨ពាន់លានរៀល ។ បើប្រៀបធៀបនឹងគ្រាដូចគ្នានៃឆ្នាំ២០០៦ ឃើញថា កើនលើស ៧២% ។ ក្នុងនោះ សាច់ប្រាក់បើកឱ្យរតនាគារជាតិមានសមាមាត្រ ៣៧% លក់ប្រាក់រៀល (ទិញដុល្លារ) ២២% ការដកប្រាក់បញ្ញើផ្សេងៗ ១៣% អគ្គិសនីកម្ពុជា ១១% និងសាច់ប្រាក់ចំណាយផ្សេងៗទៀត ១៧% ។

រីឯសកម្មភាពទទួលប្រាក់ដុល្លារអាមេរិកតាមបេឡាប្រតិបត្តិការវិញមានចំនួន ៦៦៤,៥លានដុល្លារ ។ បើប្រៀបធៀបនឹងគ្រាដូចគ្នានៃឆ្នាំ២០០៦ ឃើញថា កើនឡើង ១៥% ។ ចំណែកឯចំណាយតាមរយៈបេឡាប្រតិបត្តិការវិញមានចំនួន ៣៣៨,៦លានដុល្លារអាមេរិក ។ បើប្រៀបធៀបនឹងគ្រាដូចគ្នានៃឆ្នាំ២០០៦ ឃើញថា កើនឡើង ៥៥% ។

សកម្មភាពផ្គត់ផ្គង់ក្រដាសប្រាក់ថ្មីសម្រាប់ដូរយកក្រដាសប្រាក់ចាស់ៗខូចគុណភាពពីចរាចរណ៍មកវិញ បានធ្វើឱ្យក្រដាសប្រាក់ក្នុងចរាចរណ៍មានលក្ខណៈថ្មីស្អាតល្អ និងកាន់តែជំរុញឱ្យសាធារណជននិយមប្រើក្រដាសប្រាក់រៀលកាន់តែច្រើនឡើង ។

ក្រដាសប្រាក់ចាស់ៗដែលដូរបាន ធនាគារជាតិនៃកម្ពុជាបានធ្វើការរាប់-ស្រាវជ្រើសយ៉ាងហ្មត់ចត់ និងធ្វើការកាត់កម្ទេច និងដុតបំផ្លាញចោលតាមនីតិវិធីត្រឹមត្រូវ ។

ធនាគារជាតិនៃកម្ពុជាសហការជានិច្ចជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ការប្រើប្រាស់ក្រដាសប្រាក់ក្លែងក្លាយក្នុងចរាចរណ៍ ។

## II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សកម្មភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្នមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| - ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| - លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| - ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - ឯកឧត្តម អ៊ុំ ថុង | តំណាងមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - ឯកឧត្តម ជូ គីមឡេង | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - លោក ឡាយ ម៉េងស៊ុន | តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក |
| - លោកស្រី ម៉ៅ សុន | តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក ។ |

ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ក្រុមប្រឹក្សាភិបាលបានប្រជុំចំនួន ២ លើក ដើម្បីពិភាក្សា និងអនុម័តលើការងារមួយចំនួនដូចខាងក្រោម :

- កិច្ចប្រជុំលើកទី ៦០ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ការិយបរិច្ឆេទឆ្នាំ២០០៦
- កិច្ចប្រជុំលើកទី៦១ នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្ថានភាពថវិកាឆ្នាំ២០០៦ របស់ធនាគារជាតិនៃកម្ពុជា ។

## ២. ការអភិវឌ្ឍធនធានមនុស្ស

### ២.១. ស្ថិតិមន្ត្រី-បុគ្គលិក

- មន្ត្រី-បុគ្គលិកក្នុងក្របខ័ណ្ឌរបស់ធនាគារជាតិនៃកម្ពុជានៅទីស្នាក់ការកណ្តាល ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ មានចំនួន ៧៦៧រូប (ប្រុស ៤៣៥រូប ស្រី ៣៣២រូប) ដោយឡែកមន្ត្រី-បុគ្គលិកក្រៅក្របខ័ណ្ឌមានចំនួន ១៥រូប (ប្រុស១៤រូប ស្រី១រូប)
- មន្ត្រីរក្សាក្របខ័ណ្ឌមានចំនួន ៣រូប (ប្រុស ២រូប ស្រី ១រូប)
- ក្របខ័ណ្ឌសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង មានចំនួន ៣៦៥រូប (ប្រុស ២១០រូប ស្រី ១៥៥រូប) ។

ដូច្នេះ សរុបក្របខ័ណ្ឌមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសនៅក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ មានចំនួន១.១៣៥រូប (ប្រុស ៦៤៧រូប ស្រី ៤៨៨រូប) បើប្រៀបធៀបជាមួយក្របខ័ណ្ឌចុងខែធ្នូ ឆ្នាំ២០០៦ ដែលមានចំនួន ១០៣២រូប (ប្រុស ៥៨៧រូប ស្រី ៤៤៥រូប) គឺមានការប្រែប្រួលដូចតទៅ:

- ទីស្នាក់ការកណ្តាលកើនចំនួន ៦៤រូប (ចូល ៧៧រូប ចេញ ១៣រូប)
- សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង កើនចំនួន ៣៩រូប (ចូល ៤៧រូប ចេញ ០៨រូប) ។

### ២.២. ការងារបណ្តុះបណ្តាល

ឈរលើស្មារតីលើកកម្ពស់ការកសាងសមត្ថភាពធនធានមនុស្សនៅឆមាសទី១ ឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំវគ្គណែនាំប្រតិបត្តិការចំនួន ២វគ្គ ដោយមានមន្ត្រី-បុគ្គលិកចូលរួមចំនួន ៣៦រូប សម្រាប់បំប៉នចំណេះដឹងមន្ត្រី-បុគ្គលិកជ្រើសរើសថ្មី ដើម្បីទៅបំពេញការងារនៅសាខាធនាគារជាតិនៃកម្ពុជា និងបានចាត់បញ្ជូនមន្ត្រីចូលរួមវគ្គវិក្រឹតការនៅសាលាភូមិន្ទរដ្ឋបាលចំនួន ១លើក ដោយមានមន្ត្រីចូលរួមចំនួន ២រូប គឺ :

- វគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ចំនួន ១រូប

- វគ្គវិក្រឹតការមន្ត្រីមធ្យមចំនួន ១រូប ។

ក្រៅពីនេះ មានការធ្វើសិក្ខាសាលាចំនួន ៤លើក នៅធនាគារជាតិនៃកម្ពុជា (សរុបមន្ត្រី-បុគ្គលិកចូលរួមចំនួន ៨៩រូប) លើប្រធានបទដូចខាងក្រោម :

- ការបង្ការប្រាក់ដុល្លារអាមេរិកក្លែងក្លាយចំនួន ២លើក ឧបត្ថម្ភដោយធនាគារ HSBC សាខាសិង្ហបុរី
  + នៅទីស្នាក់ការកណ្តាលភ្នំពេញ មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ៣៣រូប
  + នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តបាត់ដំបង មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ៣៧រូប
- ការរៀបចំកម្មវិធី និងគោលនយោបាយហិរញ្ញវត្ថុ មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ១២រូប ឧបត្ថម្ភដោយ IMF-STI
- ប្រព័ន្ធទូទាត់សងប្រាក់ និងផាត់ទាត់សម្រាប់សេដ្ឋកិច្ចដែលកំពុងងើបឡើង (Payment and Settlement System for Emerging Economies) មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ៧រូប ឧបត្ថម្ភដោយមជ្ឈមណ្ឌល SEACEN ។

ក្រៅពីការបើកវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ធនាគារជាតិនៃកម្ពុជាក៏បានបញ្ជូនមន្ត្រី-បុគ្គលិកទៅចូលរួមក្នុងសិក្ខាសាលាតាមការអញ្ជើញពីបណ្តាក្រសួង-ស្ថាប័ននានាផងដែរ ក្នុងនោះមានសិក្ខាសាលាចំនួន ៣លើក (សរុបមន្ត្រី-បុគ្គលិកចូលរួមចំនួន ២៣រូប) ដែលស្តីអំពី :

- ហានិភ័យទីផ្សារ មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ១៥រូប នៅធនាគារ ANZ Royal
- ជំនាញចរចាដែលមានប្រសិទ្ធភាពកម្រិតមធ្យម មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ៤រូប នៅមជ្ឈមណ្ឌលហុងកុង តាមការអញ្ជើញពីទីភ្នាក់ងារអភិវឌ្ឍន៍ជប៉ុន (JICA)
- ការព្យាករចំណូល មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ៤រូប នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការអញ្ជើញពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំពោះការងារបណ្តុះបណ្តាលនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ គឺនិស្សិតជំនាន់ទី១៥ (ឆមាសទី២ ឆ្នាំទី២) និងជំនាន់ទី១៦ (ឆមាសទី២ ឆ្នាំទី១) មានមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាចំនួន ២០រូប កំពុងសិក្សា ។

ទន្ទឹមនឹងការបណ្តុះបណ្តាលនៅក្នុងប្រទេស ធនាគារជាតិនៃកម្ពុជាក៏បានចាត់បញ្ជូនមន្ត្រី-បុគ្គលិករបស់ខ្លួនទៅចូលរួមវគ្គសិក្សារយៈពេលខ្លីនិងវែង ទស្សនកិច្ចសិក្សា និងសិក្ខាសាលាផ្សេងៗនៅក្រៅប្រទេសផងដែរ តាមរយៈការអញ្ជើញរបស់ស្ថាប័នអន្តរជាតិនានា ដូចជា ធនាគារកណ្តាលអាល្លឺម៉ង់ (Deutsche Bundesbank) មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ធនាគារកណ្តាលកូរ៉េ (Bank of Korea) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) មជ្ឈមណ្ឌល AUSTRAC ក្រសួងហិរញ្ញវត្ថុចិន (MOF, China) មជ្ឈមណ្ឌល

សិក្សាស៊ីស (Gerzensee) ក្រុមហ៊ុន JOHS RIECKERMANN (JR) ក្រសួងហិរញ្ញវត្ថុនៃសាធារណរដ្ឋកូរ៉េ (MEF, Korea) ក្រុមហ៊ុន Securency Pty Ltd អង្គការ UNODC (United Nations Office on Drugs and Crime) ទីភ្នាក់ងារស៊ីដា (Swedish International Development Cooperation Agency (SIDA)) ធនាគារ Citigroup (Citigroup Bank) ធនាគារពិភពលោក (World Bank) អង្គការ FAO (Food and Agriculture Organization) អង្គការ ASEAN មជ្ឈមណ្ឌល SEACEN ធនាគារ HSBC អង្គការ AUSAID មជ្ឈមណ្ឌល CICF (Center for International Commerce and Finance) វិទ្យាស្ថាន IDS (Institute of Development Studies) វិទ្យាស្ថាន TDRI (Thailand Development Research Institute) ធនាគារ Dexia (Dexia Bank) រដ្ឋាភិបាលកូរ៉េ (Government of Korea) សមាគម APRACA (Asia-Pacific Rural and Agriculture Credit Association) និងអាជ្ញាធររូបិយវត្ថុសិង្ហបុរី (MAS) ។ល។

## ៣. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាបានបន្តធ្វើកំណែទម្រង់រចនាសម្ព័ន្ធរបស់អគ្គាធិការដ្ឋាន សំដៅពង្រឹងការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចឱ្យមានប្រសិទ្ធភាព ដោយបន្តរៀបចំនូវលិខិតបទដ្ឋានចាំបាច់នានាដូចជា សៀវភៅនីតិវិធីសវនកម្មសម្រាប់នាយកដ្ឋាន សាខា និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ។

បន្ទាប់ពីបានរៀបចំសម្រួលរចនាសម្ព័ន្ធ និងកំណត់នូវតួនាទីនិងភារកិច្ចរបស់មន្ត្រី-បុគ្គលិកជាសវនករ និងមន្ត្រីអធិការកិច្ចមក ការងារបណ្តុះបណ្តាលក៏បានធ្វើឡើងដើម្បីបំពាក់បំប៉នសមត្ថភាពតាមរយៈការបណ្តុះបណ្តាលទ្រឹស្តី ចុះហាត់ការងារ និងការបញ្ជូនទៅបណ្តុះបណ្តាលនៅក្រៅប្រទេស ។

ចំពោះការងារសវនកម្ម នាយកដ្ឋានដែលទទួលបានការធ្វើសវនកម្មមុនគេតាមវិធីសាកល្បង និងហ្វឹកហាត់ការងារគឺ នាយកដ្ឋានប្រតិបត្តិការ (ការិយាល័យគ្រប់គ្រងគណនី) នាយកដ្ឋានបោះផ្សាយ-ឃ្លាំងបេឡា (ការិយាល័យបេឡា និងការិយាល័យគណនេយ្យជំនួយ) និងការចុះបញ្ជីនៅនាយកដ្ឋានគណនេយ្យនិងសាខាធនាគារជាតិនៃកម្ពុជា ខេត្តសៀមរាប ។

បន្ទាប់ពីចុះធ្វើសវនកម្មសាកល្បងរួច សៀវភៅនីតិវិធីសវនកម្មសម្រាប់នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានបោះផ្សាយ-ឃ្លាំងបេឡា និងសាខាធនាគារជាតិនៃកម្ពុជា ត្រូវបានរៀបចំកែសម្រួលជាបន្តបន្ទាប់ ដើម្បីធ្វើឱ្យនីតិវិធីទាំងនេះអាចតម្រូវតាមស្ថានភាពបច្ចុប្បន្ន និងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រតិបត្តិការរបស់នាយកដ្ឋាន និងអង្គភាពទាំងនោះ ។

ចំពោះការងារអធិការកិច្ចវិញ ក៏ត្រូវបានដំណើរការយ៉ាងមមាញឹក តាមរយៈការចុះឆ្នក់ត្រួតពិនិត្យដោយមិនជូនដំណឹងមុនចំនួន ៩លើក លើ ១៩សាខា ដែលការត្រួតពិនិត្យបានផ្តោតជាសំខាន់លើការងារធានាសុវត្ថិភាពឃ្លាំង និងការងារគ្រប់គ្រងសាច់ប្រាក់ ។

## ៤. ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាបានបង្កើនការយកចិត្តទុកដាក់ចំពោះសកម្មភាពរបស់សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង ក្នុងគោលបំណងពង្រឹង និងពង្រីកសមត្ថភាពផ្តល់សេវាធនាគារកណ្តាលនៅតាមមូលដ្ឋាន ក្នុងក្របខ័ណ្ឌបន្តរួមចំណែកអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។ មិនតែប៉ុណ្ណោះ ធនាគារជាតិនៃកម្ពុជាបានចេញលិខិតជូនដំណឹងឱ្យសាខាធនាគារជាតិនៃកម្ពុជាខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប ក្រុងព្រះសីហនុ និងស្វាយរៀង បើកគណនី និងផ្តល់សេវាកម្មសម្រាប់ប្រាក់បញ្ញើអាណត្តិប្រែសណីយ៍អន្តរជាតិ និងចុះត្រួតពិនិត្យទៀងទាត់ដល់មូលដ្ឋាន ដើម្បីធានាតម្លាភាព និងភាពត្រឹមត្រូវក្នុងប្រតិបត្តិការរបស់សាខាគ្រប់ផ្នែក និងធ្វើការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនបុគ្គលិកជំនាញតាមតម្រូវការចាំបាច់របស់សាខាខេត្ត-ក្រុងនានា ។

## ៥. ការងារគណនេយ្យធនាគារជាតិនៃកម្ពុជា

ក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ទ្រព្យសកម្មធនាគារជាតិនៃកម្ពុជាបានកើនឡើងជាង ១.៧៤៦ពាន់លានរៀល គឺ ១៨,៩៧% ក្នុងនោះកំណើនដែលគួរឱ្យកត់សម្គាល់គឺបរិមាណសាច់ប្រាក់ជារៀល និងជារូបិយប័ណ្ណ ដែលមានកំណើនសរុប ១៥២ពាន់លានរៀល (៤៩%) ហើយប្រាក់បញ្ញើជារូបិយប័ណ្ណនៅស្ថាប័នហិរញ្ញវត្ថុ និងធនាគារបរទេសមានកំណើនសរុប ១.២៧៩ពាន់លានរៀល ពោលគឺកើន ៤២,៤៨% ក៏ប៉ុន្តែការវិនិយោគលើមូលប័ត្របានថយចុះ ៣១៧ពាន់លានរៀល ពោលគឺថយចុះ ១៩,៧៦% ។ ចំណែកផ្នែកទ្រព្យអកម្មវិញ រូបិយវត្ថុបានបោះផ្សាយមានកំណើន ២១២ពាន់លានរៀល ពោលគឺកើន ១១,៥២% ហើយប្រាក់បញ្ញើរបស់រដ្ឋាភិបាលមានកំណើន ៤៣០ពាន់លានរៀល គឺស្មើនឹង ៣៩,៤២% ។ ចំណែកប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជមានការកើនឡើងចំនួន ៥១៣ពាន់លានរៀល គឺស្មើនឹង ២៧,៧៦% ។

# តារាងតុល្យការធនាគារជាតិនៃកម្ពុជា

ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៧

## ទ្រព្យសកម្ម

(ឯកតាលានរៀល)

| **អត្ថាធិប្បាយ** | **ចំនួនទឹកប្រាក់**<br>ថ្ងៃ ៣១ ខែធ្នូ ឆ្នាំ២០០៦ | **ចំនួនទឹកប្រាក់**<br>ថ្ងៃ ៣០ ខែមិថុនា ឆ្នាំ២០០៧ |
|---|---|---|
| សាច់ប្រាក់ជារៀល និងជារូបិយប័ណ្ណ | ៣០៩.៦២៨ | ៤៦១.៣៥១ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ នៅធនាគារបរទេស | ៣.០១១.៦៩១ | ៤.២៩០.៩៦៨ |
| ប្រាក់ SDR នៅមូលនិធិរូបិយវត្ថុអន្តរជាតិ | ៧៦៣ | ៦៧៣ |
| ប្រាក់រៀលបង់ចូលជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ | ៥២៧.២២៩ | ៥៤២.២៦៦ |
| វិនិយោគលើមូលប័ត្របរទេស | ១.៦០៤.០៩៥ | ១.២៨៧.០៩០ |
| លោហធាតុមានតម្លៃ ផ្ញើនៅបរទេស | ១.០៣១.៩៥១ | ១.០៥៩.៥២៤ |
| ឱ្យខ្ចី និងបុរេប្រទាន | | |
| - ចំពោះធនាគារពាណិជ្ជ | ៤៣.៥២០ | ៥៩.៥២០ |
| - ចំពោះរដ្ឋាភិបាល | ២៧០.២៥៣ | ២៨៣.០៥៥ |
| អចលនទ្រព្យ | ៤១០.៧៩១ | ៤៧៨.០៩៦ |
| ផ្សេង ៗ | ១.៩៩២.៣៩៤ | ២.៤៨៥.៣៨៣ |
| **សរុប** | **៩.២០២.៣១៥** | **១០.៩៤៧.៩២៦** |

## ទ្រព្យអកម្ម

(ឯកតាលានរៀល)

| **អត្ថាធិប្បាយ** | **ចំនួនទឹកប្រាក់** | **ចំនួនទឹកប្រាក់** |
|---|---|---|
| រូបិយវត្ថុបោះផ្សាយ | ១.៨៣៧.៣១១ | ២.០៤៩.០៦១ |
| ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ | ១.៨៤៧.១៨៩ | ២.៣៦០.០២៨ |
| បំណុលចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ | ៦២៨.៧២៤ | ៦៤៤.៦៦៦ |
| ប្រាក់បញ្ញើរបស់រដ្ឋាភិបាល | ១.០៨៩.៥៤៨ | ១.៥១៩១.០៩៧ |
| ដើមទុន | ១០០.០០០ | ១០០.០០០ |
| ទុនបម្រុង | ១.៤០៩.៩៥៩ | ១.៤៦៩.៧៥១ |
| រំលស់បង្គរទុក | ៧៨.០២៩ | ៨៥.៧៨៤ |
| សវិធានធន | ១៤៥.៨៨៨ | ១៧៥.៦០៦ |
| ផ្សេង ៗ | ២.០៦៥.៦៦៧ | ២.៥៤៣.៩៣៣ |
| **សរុប** | **៩.២០២.៣១៥** | **១០.៩៤៧.៩២៦** |

# III. ទំនាក់ទំនងអន្តរជាតិ

## ១. ទំនាក់ទំនងពហុភាគី

### ១.១. ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ

នៅក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០០៧ នេះ មូលនិធិរូបយិវត្ថុអន្តរជាតិបានបន្តផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ដើម្បីពង្រឹងសវនកម្មផ្ទៃក្នុង និងធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃប្រភពទិន្នន័យស្ថិតិជញ្ជីងទូទាត់ តាមរយៈការធ្វើអង្កេតលើទិន្នន័យវិនិយោគផ្ទាល់បរទេសនៅកម្ពុជា ការអង្កេតលើទិន្នន័យចំណាយរបស់ទេសចរបរទេសនៅកម្ពុជា និងចំណាយរបស់ប្រជាជនកម្ពុជានៅបរទេស ។ ទន្ទឹមនេះដែរ មូលនិធិរូបិយវត្ថុអន្តរជាតិបានសហការជាមួយធនាគារជាតិនៃកម្ពុជារៀបចំវគ្គសិក្សាថ្នាក់ជាតិមួយ កាលពីថ្ងៃទី១២ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៧ ស្តីពី "កម្មវិធី និងគោលនយោបាយហិរញ្ញវត្ថុ" ដែលផ្តោតជាសំខាន់ទៅលើប្រភពកំណើនសេដ្ឋកិច្ចបច្ចេកទេសព្យាករណ៍ និងការវិភាគម៉ាក្រូសេដ្ឋកិច្ច សម្រាប់មន្ត្រីរាជការមកពីក្រសួងពាក់ព័ន្ធ ដូចជា ក្រសួងពាណិជ្ជកម្ម ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ។

នៅក្នុងឆមាសទី១ នេះ បេសកកម្មពិគ្រោះយោបល់នៃមាត្រា IV នៃមូលនិធិរូបិយវត្ថុអន្តរជាតិ បានមកធ្វើបេសកកម្មនៅកម្ពុជាចំនួនពីរលើក : លើកទី១ ពីថ្ងៃទី ១៤ ដល់ថ្ងៃទី២១ ខែកុម្ភៈ និងលើកទី២ ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៥ ខែមិថុនា ។ បេសកកម្មថ្មីៗនេះ បានវាយតម្លៃល្អប្រសើរលើ ស្ថានភាពកំណើនសេដ្ឋកិច្ចរបស់កម្ពុជា កម្រិតអតិផរណាទាប ចីរភាពបំណុលបរទេស និងការវិវឌ្ឍកំណែទម្រង់រចនាសម្ព័ន្ធ ដែលឈានទៅរកការកាត់បន្ថយភាពក្រីក្របានកាន់តែច្រើនឡើង ។ មិនតែប៉ុណ្ណោះ ក្រុមបេសកកម្មក៏បានទទួលស្គាល់នូវកំណើនដ៏ឆាប់រហ័សនៃវិស័យធនាគារ តាមរយៈការកើនឡើងនៃប្រាក់បញ្ញើ និងការផ្តល់ឥណទានរហូតដល់ ៤០% ដែលកំណើននេះឆ្លុះបញ្ចាំងឱ្យឃើញពីការអភិវឌ្ឍសេដ្ឋកិច្ច និងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ។ ប៉ុន្តែនៅចំពោះមុខកំណើនដ៏លឿននេះ ក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តល់អនុសាសន៍ដែរថា ធនាគារជាតិនៃកម្ពុជាត្រូវតែបង្កើនការត្រួតពិនិត្យធនាគារបន្ថែមទៀត ដើម្បីបញ្ចៀសហានិភ័យឥណទានធនាគារ ។

ចំពោះប្រតិបត្តិការហិរញ្ញវត្ថុវិញ បន្ទាប់ពីការលុបបំណុលនៅក្រោម "គំនិតផ្តួចផ្តើមលុបបំណុលជាពហុភាគី" នៅ ឆ្នាំ២០០៦រួចមក រាជរដ្ឋាភិបាលកម្ពុជាពុំទាន់បានទទួលឥណទានថ្មីពីមូលនិធិរូបិយវត្ថុអន្តរជាតិនៅឡើយទេ ។ នៅក្នុងរយៈពេលឆមាសទី ១ នេះ ប្រតិបត្តិការហិរញ្ញវត្ថុជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិមានការទទួល និងសងការប្រាក់ និងកម្រៃមួយចំនួនចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ ដូចតទៅ ÷

- ការទទួលការប្រាក់ពីការរក្សាសិទ្ធិដកពិសេស (SDRs Holdings) នៅមូលនិធិរូបិយវត្ថុអន្តរជាតិមានចំនួន ២.២០១ SDRs ស្មើនឹង ៣.៣២៣ ដុល្លារអាមេរិក ។
- ការសងកម្រៃពាក់ពន្ធ័នឹងការបែងចែកសិទ្ធិដកពិសេស (SDRs allocations) មានចំនួន ៣១៨,១ពាន់ SDRs ស្មើនឹង ៤៨០,៨ពាន់ដុល្លារអាមេរិក ។

## ១.២. ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី

គួររំឭកថា ក្រោយពីបានបំពេញលក្ខខណ្ឌការងារនៅក្នុងអនុកម្មវិធីទី១ និងទី២ ដែលមានចែងនៅក្នុងឯកសារ "ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០០១-២០១០" ចប់រួចមក រាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ីក៏បានចុះហត្ថលេខាលើគម្រោងឥណទានសម្រាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុលើអនុកម្មវិធីទី ៣ ទៀត ដែលមានប្រាក់ចំនួន ១០លានដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ១% នៅខែវិច្ឆិកា ឆ្នាំ២០០៥ ។ ការងារកំណែទម្រង់មួយចំនួននៅក្នុងអនុកម្មវិធីទី៣ ដែលពាក់ព័ន្ធនឹងធនាគារជាតិនៃកម្ពុជាត្រូវបានបំពេញចប់សព្វគ្រប់នៅចុងឆ្នាំ២០០៦ ដូចជាការរៀបចំច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងការដាក់ឱ្យប្រើនូវប្រកាសចំនួន ៣ ពាក់ព័ន្ធនឹងការអនុវត្តច្បាប់នេះជាដើម ។ ចំណែកឯច្បាប់ស្តីពីការប្រឆាំងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានរដ្ឋសភាអនុម័តឱ្យប្រើប្រាស់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៧ ថ្មីៗនេះ ។ បច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាកំពុងដំណើរការរៀបចំកែលំអប្រកាស បទប្បញ្ញត្តិផ្សេងៗដែលមានស្រាប់ ដើម្បីសម្របតាមច្បាប់ថ្មីនេះ ។ ទន្ទឹមនោះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្នក៏ត្រូវបានបង្កើតហើយដែរ ។ អនុកម្មវិធីទី ៣ ត្រូវបានរំពឹងថា នឹងបញ្ចប់សព្វគ្រប់ជាស្ថាពរ នៅក្នុងត្រីមាសទី៣ ខាងមុខ ។

ក្រោមគម្រោងអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម សេចក្តីព្រាងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ហើយនឹងត្រៀមដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីនាពេលឆាប់ៗ ។ ចំណែកការងារទាក់ទងនឹងប្រព័ន្ធចែករំលែកព័ត៌មានឥណទានវិញ បន្ទាប់ពីធនាគារជាតិនៃកម្ពុជាសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ីរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាននេះជាផ្លូវការកាលពីខែសីហា ឆ្នាំ២០០៦ កន្លងមកបច្ចុប្បន្ននេះកំពុងតែដំណើរការទៅមុខ និងកំពុងត្រូវបានកែលំអប្រព័ន្ធជាបន្តបន្ទាប់ ។

ទន្ទឹមនោះដែរ ដើម្បីរក្សានិរន្តរភាព និងសន្ទុះនៃការរីកចម្រើនសេដ្ឋកិច្ច ក្នុងឆមាសទី១ ឆ្នាំ២០០៧នេះ ឯកសារ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" ដែលជាការធ្វើបច្ចុប្បន្នកម្មនៃ "ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០" ត្រូវបានទទួលការអនុម័តិនៅក្នុងកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៧ ។ មិនតែប៉ុណ្ណោះ យុទ្ធសាស្ត្រថ្មីនេះត្រូវបានសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅក្នុងសន្និសីទថ្នាក់ជាតិស្តីពី "ភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ឆ្ពោះទៅរកប្រព័ន្ធហិរញ្ញវត្ថុដែលសមាហរណកម្ម និងរឹងមាំ" នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧ ។ ឯកសារនេះជាឯកសារមេសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជានាពេលបច្ចុប្បន្ន និងទៅអនាគត ។ ដើម្បីអនុវត្តឯកសារយុទ្ធសាស្ត្រនេះឱ្យមានប្រសិទ្ធភាព របាយការណ៍ដំបូងមួយត្រូវបានរៀបចំធ្វើឡើងក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (TA-4835) ដើម្បីសិក្សា រៀបចំកម្មវិធីឥណទានថ្មីមួយទៀតព្រមជាមួយការផ្តល់ជំនួយបច្ចេកទេស ដើម្បីទ្រទ្រង់រាល់វិស័យការងារដែលមានចែងនៅក្នុងឯកសារយុទ្ធសាស្ត្រ ។

### ១.៣. ទំនាក់ទំនងជាមួយអាស៊ាន

សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន និងអាស៊ាន+៣ (ចិន កូរ៉េ ជប៉ុន) មានដំណើរការទៅមុខយ៉ាងរលូន ដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់ស្ថាប័នពាក់ព័ន្ធនៃប្រទេសជាសមាជិកទាំងឡាយ រួមទាំងធនាគារជាតិនៃកម្ពុជាផងដែរ ។ ក្នុងអំឡុងឆមាសទី១ នេះ ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំសំខាន់ៗពីរគឺ កិច្ចប្រជុំថ្នាក់ទេសាភិបាល និងថ្នាក់ទេសាភិបាលរងនៃធនាគារកណ្តាលអាស៊ានទាំង ១០ នៅទីក្រុងឈៀងម៉ៃ ប្រទេសថៃ និងកិច្ចប្រជុំថ្នាក់ទេសាភិបាលរងនៃធនាគារកណ្តាលនិងកិច្ចប្រជុំនៃរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន+៣ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ។ ផ្អែកលើផែនការយុទ្ធសាស្ត្រនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC Blueprint) ការអនុវត្តមាគ៌ាសម្រាប់សមាហរណកម្មរូបិយវត្ថុ និងហិរញ្ញវត្ថុអាស៊ាន (Roadmap for monetary and financial intergration of Asean) ចាំបាច់ត្រូវបានពង្រឹង និងបង្កើនល្បឿនបន្ថែមទៀត ដើម្បីប្រែក្លាយអាស៊ានឱ្យទៅជាតំបន់ដែលទំនិញ សេវា វិនិយោគ ពលកម្ម និងដើមទុន មានចលនាដោយសេរីនៅឆ្នាំ២០១៥ ស្របតាមស្មារតីនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី១២ ក្នុងនោះ សហប្រតិបត្តិការចម្បង៧ពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុរួមមាន : ការអភិវឌ្ឍទីផ្សារទុន ការធ្វើសេរីភាវូបនីយកម្មគណនីដើមទុន ការធ្វើសេរីភាវូបនីយកម្មសេវាកម្មហិរញ្ញវត្ថុ និងសហប្រតិបត្តិការផ្នែករូបិយវត្ថុ ។ ទន្ទឹមនោះ ដោយយល់ដល់សារៈសំខាន់នៃការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តចំពោះភាពលូតលាស់នៃសេដ្ឋកិច្ចក្នុងអាស៊ាន បណ្តាថ្នាក់ដឹកនាំនៃវិស័យធនាគារនិងហិរញ្ញវត្ថុអាស៊ាន ក៏បានឯកភាពផ្តួចផ្តើមការសិក្សាអំពីការធ្វើហិរញ្ញប្បទានចំពោះហេដ្ឋារចនាសម្ព័ន្ធរូបវន្តផងដែរ ។ ដោយឡែក ក្នុងបរិបទប្រកបដោយនិន្នាការរីកលូតលាស់ដ៏លឿននៃសកលភាវូបនីយកម្ម ធនាគារកណ្តាលអាស៊ានទាំង ១០ កំពុងត្រៀមលក្ខណៈចរចាលើវិស័យហិរញ្ញវត្ថុជាមួយប្រទេសកូរ៉េ នូវ៉ែលហ្សេឡង់ អូស្ត្រាលី ជាបណ្តើរៗដែរ ។

### ១.៤. ទំនាក់ទំនងជាមួយ SEACEN

បន្ទាប់ពីបានចូលជាសមាជិករបស់ SEACEN (South-East Asian Central Banks) កាលពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៦ មក ធនាគារជាតិនៃកម្ពុជាមានឱកាសពង្រីកសហប្រតិបត្តិការបែងចែកព័ត៌មានគ្នាទៅវិញទៅមក រវាងធនាគារកណ្តាលជាសមាជិក ហើយផ្តល់អត្ថប្រយោជន៍ និងបទពិសោធន៍ដ៏ច្រើនសម្រាប់អនុវត្តគោលនយោបាយរូបិយវត្ថុ និងបណ្តុះបណ្តាលធនធានមនុស្ស ពង្រឹងគុណភាពការងារ និងអភិវឌ្ឍវិស័យធនាគារ ។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជាបានចូលរួមជាលើកដំបូងក្នុងការសិក្សា ស្រាវជ្រាវ ក្នុងក្របខ័ណ្ឌការងារស្រាវជ្រាវនៃវិទ្យាស្ថាន SEACEN លើប្រធានបទ "ឥទ្ធិពលនៃការឡើងថ្លៃប្រេងឥន្ធនៈមកលើសេដ្ឋកិច្ចនៃបណ្តាប្រទេស SEACEN និងផលប៉ះពាល់នយោបាយ" ។ លើសពីនេះទៀត ជារៀងរាល់ត្រីមាស ធនាគារជាតិនៃកម្ពុជាតែងផ្ញើរបាយការណ៍ស្តីពីការវិវត្តម៉ាក្រូសេដ្ឋកិច្ច កំណែទម្រង់វិស័យធនាគារនិងហិរញ្ញវត្ថុ និងអំពីសកម្មភាពរបស់ធនាគារជាតិនៃកម្ពុជា ដល់មជ្ឈមណ្ឌល SEACEN សម្រាប់ធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

កាលពីថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៧ គណៈប្រតិភូរបស់ធនាគារជាតិនៃកម្ពុជាបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំលើកទី ៥ របស់គណៈកម្មការប្រតិបត្តិ ដែលបានរៀបចំឡើងនៅប្រទេសប្រ៊ុយណេដារុយសាឡាម ហើយដែលមានការចូលរួមពីបណ្តាប្រទេសជាសមាជិកទាំង ១៥ និងនាយកប្រតិបត្តិរបស់ SEACEN ។ របៀបវារៈសំខាន់នៃកិច្ចប្រជុំ គឺការពិនិត្យមើលកម្មវិធីសកម្មភាពរបស់មជ្ឈមណ្ឌល SEACEN សម្រាប់ឆ្នាំប្រតិបត្តិការ ២០០៦-២០០៧ កម្មវិធីបណ្តុះបណ្តាលដែលស្នើឡើងសម្រាប់ឆ្នាំប្រតិបត្តិការ ២០០៧-២០០៨ គម្រោងថវិកាដែលបានស្នើឡើងសម្រាប់ឆ្នាំ២០០៧-២០០៨ និងបញ្ហាមួយចំនួនទៀតទាក់ទងនឹងកម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌល ។

ទន្ទឹមនេះដែរ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយ SEACEN រៀបចំសិក្ខាសាលា ស្តីពី **ប្រព័ន្ធទូទាត់ និងផាត់ទាត់ សម្រាប់ប្រទេសកំពុងអភិវឌ្ឍ** នៅខេត្តសៀមរាប កាលពីថ្ងៃទី ៣០ ខែមេសា ដល់ថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០០៧ ដោយមានការចូលរួមពីសិក្ខាកាមមកពីធនាគារកណ្តាលនៃប្រទេសសមាជិកទាំង ១៦ ។

## ១.៥. ទំនាក់ទំនងជាមួយក្រុមអាស៊ីប៉ាស៊ីហ្វិក (APG)

កម្ពុជាបានចូលជាសមាជិកក្រុមអាស៊ីប៉ាស៊ីហ្វិកនៅឆ្នាំ២០០៤ ដោយធនាគារជាតិនៃកម្ពុជាបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងឋានៈជាអ្នកទំនាក់ទំនងចម្បង (Primering contact point) រវាង APG ជាមួយក្រសួង និងអង្គភាពពាក់ព័ន្ធនានានៅកម្ពុជា ជាពិសេសក្នុងការទទួលជំនួយបច្ចេកទេសពី APG លើការងារបណ្តុះបណ្តាល និងការត្រៀមខ្លួនសម្រាប់បង្កើតក្រុមស៊ើបការណ៍ហិរញ្ញវត្ថុ ។ នៅខែមីនា ឆ្នាំ២០០៧ ធនាគារពិភពលោក និង APG បានមកធ្វើការវាយតម្លៃអញ្ញមញ្ញ (Mutual Evaluation) ចំពោះប្រទេសកម្ពុជា ។ តាមរយៈសកម្មភាពនេះ យើងបានដឹងចំណុចខ្វះខាតផ្សេងៗដែលនឹងត្រូវជំនះជាបណ្តើរៗ ដើម្បីឆ្លើយតបចំពោះអនុសាសន៍ទាំង ៤០ និងអនុសាសន៍ពិសេស ៩ របស់ FATF ។

## ១.៦. ទំនាក់ទំនងជាមួយសមាគមឥណទានកសិកម្ម និងឥណទានជនបទអាស៊ីប៉ាស៊ីហ្វិក (APRACA)

ធនាគារជាតិនៃកម្ពុជាបានចូលជាសមាជិកសមាគមឥណទានកសិកម្ម និងឥណទានជនបទអាស៊ីប៉ាស៊ីហ្វិក (APRACA) នៅឆ្នាំ២០០០ ក្នុងទិសដៅពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងផ្លាស់ប្តូរបទពិសោធន៍ បច្ចេកវិទ្យាទៅវិញទៅមក តាមរយៈការបណ្តុះបណ្តាលផ្នែកឥណទានកសិកម្មជនបទ និងការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ក្នុងនាមជាសមាជិក ធនាគារជាតិនៃកម្ពុជាបានចូលរួមសកម្មភាពបណ្តុះបណ្តាលនានា ដែលរៀបចំដោយ APRACA ដើម្បីរួមចំណែកបង្កើនសមត្ថភាពត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

នៅដើមឆ្នាំ២០០៧ នេះ ធនាគារជាតិនៃកម្ពុជាបានបញ្ជូនមន្ត្រីសម្រាប់ទៅចូលរួមវេទិកា សិក្ខាសាលាវគ្គសិក្សា និងទស្សនកិច្ចសិក្សា ដែលរៀបចំដោយ APRACA តាមប្រធានបទមួយចំនួនដូចខាងក្រោម :

- វេទិកាស្តីពីបរិយាកាសគោលនយោបាយហិរញ្ញវត្ថុជនបទ និងក្របខ័ណ្ឌបទប្បញ្ញត្តិ នៅប្រទេសចិន
- វគ្គសិក្ខាសាលាអំពីការជំរុញឱ្យមានការធានារ៉ាប់រងលើផលកសិកម្ម នៅប្រទេសឥណ្ឌូណេស៊ី
- វគ្គសិក្សាអំពីការគ្រប់គ្រងឥណទានមានបញ្ហា នៅប្រទេសម៉ាឡេស៊ី
- វគ្គសិក្សាអំពីការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានទៅឱ្យវិស័យកសិកម្ម នៅប្រទេសថៃ
- វគ្គសិក្សាអំពីការអភិវឌ្ឍសហគ្រាសធុនតូច នៅប្រទេសហ្វីលីពីន ។

## ២. ទំនាក់ទំនងទ្វេភាគី

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងទំនាក់ទំនងទ្វេភាគីជាមួយបណ្តាប្រទេសជាមិត្ត ទាំងនៅក្នុងតំបន់អាស៊ី ក៏ដូចជានៅអឺរ៉ុប លើគោលការណ៍នៃសហប្រតិបត្តិការជំនាញ ដូចជា ការសិក្សាអង្កេតរួមគ្នា ការផ្លាស់ប្តូរព័ត៌មាន និងការបណ្តុះបណ្តាលមន្ត្រីជាដើម ។

នៅក្នុងឆមាសទី១ ឆ្នាំ២០០៧នេះ ធនាគារជាតិនៃកម្ពុជាបានធ្វើការសិក្សាអង្កេតរួមគ្នាជាមួយធនាគារកណ្តាលថៃលើប្រធានបទស្តីពី "ការធ្វើពាណិជ្ជកម្មឆ្លងដែន ការវិនិយោគ និងផ្លូវដឹកជញ្ជូនទំនិញនៅកម្ពុជា" ។ ការសិក្សានេះបានធ្វើនៅតាមបណ្តាខេត្ត និងតំបន់សេដ្ឋកិច្ចពិសេសមួយចំនួន ក្នុងគោលបំណងជំរុញសហប្រតិបត្តិការធនាគារ ពាណិជ្ជកម្មឆ្លងដែន ការវិនិយោគ និងផ្លូវដឹកជញ្ជូនទំនិញនៅកម្ពុជា ។

## សន្និដ្ឋាន

ស្ថានភាពរឹងមាំជាទូទៅនៃសេដ្ឋកិច្ចពិភពលោក ជាពិសេសការបន្តសន្ទុះកំណើនសេដ្ឋកិច្ចនៃប្រទេសក្នុងតំបន់ និងប្រទេសដែលជាដៃគូពាណិជ្ជកម្មជាមួយកម្ពុជា ជាកត្តាមួយបានរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។ ក្នុងឆមាសទី១ ឆ្នាំ២០០៧ កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅតែបន្តរក្សាបានភាពខ្លាំងរបស់ខ្លួនដដែល ដែលទ្រទ្រង់ដោយការនាំចេញសម្លៀកបំពាក់ និងការរីកចំរើននៃវិស័យទេសចរណ៍ ។ ទន្ទឹមនឹងនេះដែរ ស្ថានភាពវិស័យធនាគារនិងហិរញ្ញវត្ថុក៏បង្ហាញនូវភាពរឹងមាំ ដែលឆ្លុះបញ្ចាំងជាអាទិ៍នៅក្នុងកំណើននៃអន្តរការិយកម្មធនាគារ និងកំណើនតម្រូវការប្រាក់រៀល ខណៈដែលអតិផរណានៅតែរក្សាកម្រិតទាប និងមានស្ថិរភាពអត្រាប្តូរប្រាក់គួរឱ្យកត់សម្គាល់ ។ ទាំងនេះជាលទ្ធផលនៃការខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការរក្សាស្ថិរភាពនយោបាយ និងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយត្ន័ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រដែលជាទិសដៅជាអាទិភាពរបស់រាជរដ្ឋាភិបាល ។

ស្របពេលនេះដែរ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិតាមរយៈការខិតខំធ្វើឱ្យវិស័យធនាគារ និងហិរញ្ញវត្ថុមានភាពកាន់តែរឹងមាំ ។ ក្នុងបរិបទនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់នូវបទប្បញ្ញត្តិធនាគារថ្មីៗមួយចំនួនដូចជា វិធានការពាក់ព័ន្ធនឹងការសំអាតប្រាក់ និងការប្រឆាំងហិរញ្ញប្បទានភេរវកម្ម ហើយកំពុងរៀបចំសេចក្តីព្រាងច្បាប់ភតិសន្យាហិរញ្ញវត្ថុផងដែរ ។ បន្ថែមពីលើនេះ ដើម្បីរក្សាបាននូវប្រព័ន្ធធនាគារមួយប្រកបដោយភាពរឹងមាំ និងមានជំនឿទុកចិត្តពីសាធារណជន ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការត្រួតពិនិត្យធនាគារ និងតាមដានប្រព័ន្ធហិរញ្ញវត្ថុក្នុងស្រុកដោយប្រុងប្រយ័ត្នខ្ពស់ ដើម្បីបញ្ចៀសវិបត្តិហិរញ្ញវត្ថុ ។

ជាមួយគ្នានេះ សមិទ្ធផលជាទីមោទនៈរបស់ធនាគារជាតិនៃកម្ពុជា គឺការចូលរួមរៀបចំសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" ដែលជាលទ្ធផលនៃការធ្វើបច្ចុប្បន្នកម្ម "ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០" ។ ផែនការយុទ្ធសាស្ត្ររយៈពេលវែងនេះ ត្រូវបានរាជរដ្ឋាភិបាលដាក់ឱ្យអនុវត្ត និងប្រើប្រាស់ជាផ្លូវការនៅក្នុងខែមិថុនា ឆ្នាំ២០០៧ នេះ ។

ចំណែកឯការអភិវឌ្ឍធនធានមនុស្សនៅតែបន្តពង្រឹងជាប្រចាំ ដោយនាំមកនូវផ្លែផ្កាជាបណ្តើរៗចំពោះធនាគារជាតិនៃកម្ពុជា ។ ដោយឡែក ការបន្តពង្រឹងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នជាតិ និងអន្តរជាតិ ក៏បានរួមចំណែកយ៉ាងច្រើននៅក្នុងការអភិវឌ្ឍធនធានមនុស្ស ស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធនៃវិស័យធនាគារនិងហិរញ្ញវត្ថុរបស់កម្ពុជាដែរ ។

ទោះបីបានទទួលសមិទ្ធផលជាទីមោទនៈក៏ដោយ ក៏ធនាគារជាតិនៃកម្ពុជានៅតែមានការប្រុងប្រយ័ត្នជានិច្ចក្នុងការទទួលខុសត្រូវអនុវត្តនយោបាយរូបិយវត្ថុដ៏ត្រឹមត្រូវមួយ ដើម្បីលើកស្ទួយវិស័យធនាគារ និងហិរញ្ញវត្ថុប្រកប

ដោយចីរភាព និងប្រសិទ្ធភាពខ្ពស់ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

នៅពេលដែលរាល់ការងារដែលបានកំណត់ក្នុងទិសដៅ ក្នុងគោលនយោបាយ និងក្នុងយុទ្ធសាស្ត្រ ត្រូវបានអនុវត្តរលូន និងសម្រេចដោយជោគជ័យនោះ យើងនឹងទទួលបាននូវប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ដែលកាន់តែរឹងមាំស៊ីជម្រៅ មានគណនេយ្យភាព និងតម្លាភាព ទាក់ទាញបាននូវជំនឿទុកចិត្តពីសាធារណជនកាន់តែច្រើនឡើង ។

# ខ. ទិសដៅការងារឆមាសទី២
# ឆ្នាំ២០០៧

## ទិសដៅការងារឆមាសទី២ ឆ្នាំ២០០៧

ផ្អែកតាមគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ព្រមទាំងបរិដ្ឋានអំណោយផលទាំងក្នុង និងក្រៅប្រទេស នៅឆ្នាំ២០០៧ សេដ្ឋកិច្ចត្រូវបានគ្រោងថា នឹងមានកំណើន ៩% ឯអត្រាអតិផរណាប្រចាំឆ្នាំត្រូវបានរំពឹងថា នឹងអាចរក្សាក្នុងកម្រិត ៣,៦% ខណៈដែលអត្រាប្តូរប្រាក់ នឹងមានស្ថិរភាពសមស្របសម្រាប់សម្រួលដល់សកម្មភាពសេដ្ឋកិច្ច ។ យោងតាមលទ្ធផលដែលសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០០៧ នេះ ទិសដៅដំបូងដែលបានកំណត់សម្រាប់ឆ្នាំ២០០៧ ទាំងមូល ត្រូវបានពិនិត្យមើលឡើងវិញ និងត្រូវបានកែលំអផ្អែកលើលក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ន ។ ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុសមស្រប និងមានលក្ខណៈទន់ភ្លន់ទៅតាមការវិវត្តជាក់ស្តែងនៃសេដ្ឋកិច្ច ព្រមទាំងបន្តយកចិត្តទុកដាក់រក្សាឱ្យមានលក្ខណៈស៊ីគ្នាជាមួយនឹងគោលនយោបាយសារពើពន្ធ ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានកំណត់ទិសដៅឆមាសទី២ ឆ្នាំ២០០៧ សម្រាប់ការងារសំខាន់ៗ ដូចខាងក្រោម :

### ១~ ការងាររូបិយវត្ថុ (បំរែបម្រួលជាភាគរយប្រចាំឆ្នាំ)

| | |
|---|---|
| - រូបិយវត្ថុទូទៅ (M2) | ៤៣% |
| - រូបិយវត្ថុក្នុងចរាចរណ៍ | ៣២% |
| - ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៤៧% |
| - ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា | - ២២% |
| - ឥណទានសុទ្ធចំពោះរដ្ឋាភិបាលពីវិស័យធនាគារ | - ៤% |
| - ទុនបម្រុងផ្លូវការសុទ្ធ | ២៥% |

### ២~ ការងារប្តូរប្រាក់

- បន្តតាមដានការវិវត្តនៃអត្រាប្តូររូបិយប័ណ្ណ និងស្ថានភាពទីផ្សារអន្តរជាតិ
- បន្តសិក្សាស្វែងយល់អំពីសេវារក្សាមូលប័ត្រ និងការឱ្យខ្ចីមូលប័ត្រ (Securities lending)
- បន្តរៀបចំសេចក្តីព្រាងប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតសម្រាប់សេវាប្តូររូបិយប័ណ្ណ
- ធ្វើការសិក្សាលទ្ធភាពវិនិយោគលើសញ្ញាប័ណ្ណរយៈពេលវែង ។

### ៣~ ការងារអភិវឌ្ឍប្រព័ន្ធទូទាត់

- រៀបចំគោលនយោបាយទូទាត់
- រៀបចំផែនទីចង្អុលផ្លូវសម្រាប់អភិវឌ្ឍន៍ប្រព័ន្ធទូទាត់តាមលំដាប់លំដោយអាទិភាព
- រៀបចំឯកសារចាំបាច់ និងធ្វើការបណ្តុះបណ្តាលមន្ត្រី-បុគ្គលិក Payment Policy Unit ។

## ៤. ការងារត្រួតពិនិត្យ

- ពង្រឹងការអនុវត្តច្បាប់ បទបញ្ញាប្រុងប្រយ័ត្ន
- បន្តអនុវត្តកម្មវិធីកុំព្យូទ័រ COBRA ឱ្យបានពេញលេញ
- បន្តការអនុវត្តត្រួតពិនិត្យដល់ទីកន្លែងលើគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ តាមវិសាលភាពពេញលេញ និងតាមមុខសញ្ញា
- បន្តជម្រះបញ្ជីធនាគារដែលបានបិទទ្វារ និងខិតខំប្រមែប្រមូលបំណុល ដើម្បីទូទាត់សងប្រាក់បញ្ញើអតិថិជន
- រៀបចំបទបញ្ញា ប្រកាសថ្មី ឬធ្វើវិសោធនកម្មលើប្រកាសដែលមានស្រាប់តាមការចាំបាច់ ។

## ៥. ការងារប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

- រៀបចំបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ
- រៀបចំអនុក្រឹត្យ ប្រកាស និងបទប្បញ្ញត្តិ ដើម្បីអនុវត្តច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

## ៦. ការងារគណនេយ្យ

- បន្តអនុវត្តគម្រោងកំណែទម្រង់ការងារគណនេយ្យ និងកែសម្រួលកម្មវិធីគណនេយ្យក្នុងប្រព័ន្ធកុំព្យូទ័រដែលកំពុងប្រើប្រាស់ឱ្យកាន់តែល្អប្រសើរ
- បូកសរុប និងធ្វើការវិភាគរបាយការណ៍គណនេយ្យឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា ។

## ៧. ការងារប្រតិបត្តិការ

- ពង្រឹងនិងត្រួតពិនិត្យការអនុវត្តការងារផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក ដើម្បីធានាគុណភាពទូទាត់ក្នុងប្រព័ន្ធធនាគារទាំងមូល
- បង្កើនកិច្ចសហការជាមួយនាយកដ្ឋានពន្ធដារ ទីចាត់ការគយនិងរដ្ឋាករ រតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការងារប្រមូលចំណូលប្រាក់ពន្ធពីអ្នកបង់ពន្ធដោយផ្ទាល់ និងការងារផ្សេងទៀតក្នុងក្របខ័ណ្ឌប្រព័ន្ធកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព

- ធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រតិបត្តិការគ្រប់គ្រងគណនីតាមប្រព័ន្ធកុំព្យូទ័រឱ្យស្របតាមសំណូមពរការងារ និងរចនាសម្ព័ន្ធដែលមានការកែសម្រួល ដើម្បីផ្តល់សេវាដល់អតិថិជនឱ្យបានកាន់តែឆាប់រហ័សទាន់ចិត្ត ។

## ៨. ការងារបោះផ្សាយ-ឃ្លាំងបេឡា

- បន្តចុះត្រួតពិនិត្យសាច់ប្រាក់ និងណែនាំអំពីការងារគ្រប់គ្រងសាច់ប្រាក់ ការថែរក្សាការពារឃ្លាំងប្រាក់ ព្រមទាំងតាមដានជាប្រចាំសមតុល្យសាច់ប្រាក់ និងតម្រូវការសាច់ប្រាក់របស់សាខាធនាគារជាតិនៃកម្ពុជា
- បន្តសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច រាំងខ្ទប់នូវរាល់ការក្លែងបន្លំចាយវាយប្រាក់ក្លែងក្លាយ
- ពង្រឹងការងាររាប់ស្រាល់ជ្រើស ការងារកាត់កម្ទេច និងដុតបំផ្លាញចោលក្រដាសប្រាក់ចាស់ទក់រហែកតាមគោលការណ៍ដែលបានកំណត់ ។

## ៩. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

- បន្តរៀបចំកំណត់ត្រាការងារ និងពិភាក្សាពីចំណុចរកឃើញក្នុងនីតិវិធីនៃការអនុវត្តក្នុងប្រតិបត្តិការស្តីពី លំហូរសាច់ប្រាក់ជាក់ស្តែងនៅនាយកដ្ឋានបោះផ្សាយ-ឃ្លាំងបេឡា
- ចុះធ្វើសវនកម្មនៅនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងនៅសាខាធនាគារជាតិនៃកម្ពុជា
- ចុះពង្រឹងការងារ និងធ្វើអធិការកិច្ចនៅសាខាធនាគារជាតិនៃកម្ពុជា ។

## ១០. ការបណ្តុះបណ្តាល

- សហការរៀបចំប្រព័ន្ធបណ្តាញ (Network) ជាមួយការិយាល័យព័ត៌មានុសាស្ត្រ ដើម្បីឱ្យមន្ត្រីបុគ្គលិកបានស្រាវជ្រាវ និងសិក្សាព័ត៌មានថ្មីៗបន្ថែម
- រៀបចំការប្រឡងជ្រើសរើសនិស្សិតថ្មី ចូលរៀនជំនាន់ទី១៧ សម្រាប់ឆ្នាំសិក្សា ២០០៧-២០០៨ ។

✧✧✧✧✧✧✧✧